ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការប្រើប្រាស់ដីក្នុង ឃុំប៉ុង

## ឆ្នាំ ២០០៩-២០២២

## ស្រុកវ៉ឺនសៃ ខេត្តរតនគិរី



**រៀបចំដោយៈ** គណៈកម្មាធិការផែនការ និងថវិកា/ក្រុមប្រឹក្សាឃុំ/សង្កាត់

**គាំទ្រដោយៈ** ក្រុមសម្របសម្រួលស្រុក និងសម្របសម្រួលផែនការប្រើប្រាស់ដីធ្លីថ្នាក់ស្រុក

ខែ ធ្នូ ឆ្នាំ ២០០៩

# មាតិកា


**អារម្ភកថា** ០៣

**សេចក្តីផ្តើម** ០៤

**ជំពូក១:  ព័ត៌មាន  និងទិន្នន័យសំរាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ** ០៥

**១.១  ស្ថានភាពទូទៅ** ០៥

១.១.១  ទីតាំងរដ្ឋបាល ០៥

១.១.២  ប្រជាសាស្ត្រ ០៧

១.១.៣  ភាពគ្មានដីធ្លី ០៨

១.១.៤ ស្ថានភាពសេដ្ឋកិច្ច ០៩

១.១.៥  ស្ថានភាពអប់រំ និងសិក្សាធិការ ១០

១.១.៦  ស្ថានភាពសុខាភិបាល ១១

១.១.៦.១  ផ្នែកសុខាភិបាល ១១

១.១.៦.២  ការផ្គត់ផ្គង់ទឹកស្អាត ១៣

**១.២  ស្ថានភាពភូមិសាស្ត្រ** ១៤

១.២.១  ទីតាំងភូមិសាស្ត្រ ១៤

១.២.២  អាកាសធាតុ ១៥

១.២.៣  ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន ១៥

**១.៣  ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន** ១៦

១.៣.១  ស្ថានភាពនៃការប្រើប្រាស់ដី ១៦

១.៣.២  ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដី ១៧

១.៣.៣  ស្ថានភាពកសិកម្ម ១៨

១.៣.៤  ធនធានធម្មជាតិ ២២

១.៣.៤.១  ធនធានព្រៃឈើ ២២

១.៣.៤.២  ធនធានជលផល ២២

**១.៤  ទីផ្សារ និងខ្សែសង្វាក់ផលិតផល** ២៣

១.៤.១  ទីផ្សារ និងតំលៃកសិផល ផល-អនុផលព្រៃឈើ និងផលនេសាទ ២៣

១.៤.២  ខ្សែសង្វាក់ និងចរាចរផលិតផល ២៣

១.៤.៣  ឱកាស និងឧបស័គ្គ ២៣

**ជំពូក២:  ការវិភាគតំរូវការសំរាប់អនាគត** ២៥

២.១ តំបន់រសើប ២៥
២.២ ការប្រឈម/ ឧបស័គ្គ ២៥
២.៣ តំរូវការនៃការអភិវឌ្ឍន៍ និងគោលដៅយុទ្ធសាស្ត្រឃុំ ២៦
២.៤ តំរូវការដីសំរាប់អនាគត ២៧
២.៤.១ ប្រជាសាស្ត្រ ២៧
២.៤.១.១ អត្រាកំណើន ២៧
២.៤.១.២ ការធ្វើចំណោលប្រជាសាស្ត្រ ២៨
២.៤.២ តំរូវការដីសំរាប់លំនៅដ្ឋាន ២៩
២.៤.៣ តំរូវការដីកសិកម្ម ២៩
២.៤.៤ តំរូវការដីសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ៣០
២.៤.៥ តំរូវការដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធសង្គម ៣០
២.៤.៥.១ តម្រូវការសាលារៀន ៣១
២.៤.៥.២ សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត ៣២
ក. សេវាកម្មសុខភាព ៣២
ខ. ការផ្គត់ផ្គង់ទឹកស្អាត ៣២
២.៤.៥.៣ ផ្នែកវប្បធម៌ និងសាសនា ៣៣
២.៤.៥.៤ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងប្រព័ន្ធស្រោចស្រព ៣៣
**ជំពូក៣: ផែនការប្រើប្រាស់ដីពេលអនាគត ឆ្នាំ២០០៩ ដល់ ២០២២** ៣៥
**៣.១ ស្ថានភាពដី សក្តានុពលដី និងតំរូវការដី** ៣៥
៣.១.១ ស្ថានភាពដីទូទៅ និងសក្តានុពល ៣៥
៣.១.២ តំរូវការដីតាមប្រភេទ ៣៥
**៣.២ ការបែងចែកដីតាមតម្រូវការប្រើប្រាស់** ៣៧
៣.២.១ ការវិភាគអន្តរអំពើ ៣៧
៣.២.២ ផែនទីប្រើប្រាស់ដីនាពេលអនាគត ៣៧
៣.២.៣ ការបរិយាយការប្រើប្រាស់តាមក្បាលដី ៣៨

# អារម្ភកថា

របាយការណ៍ស្តីអំពីផែនការប្រើប្រាស់ដីនៅក្នុងឃុំប៉ុង ឆ្នាំ២០២២ត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សាឃុំប៉ុង និង មានការចូលរួមពីប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ ដោយមានការចូលរួមជួយពីក្រុមអ្នកសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដី (D_LUP) ស្រុកវឺនសៃ សហការចូលរួមសម្របសម្រួលពីក្រុមអ្នកសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដី(P_LUP) ខេត្តរតនគីរី និងគាំទ្របច្ចេកទេសពីក្រុមការងារសមាសភាគរៀបចំដែនដី(Land Management Component) របស់អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្មនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ក្រោមការជួយឧបត្ថម្ភថវិកាពីអង្គការ DANIDA/DFID-NZaid តាមរយៈស្ថានទូត ដាណឺម៉ាក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។ គោលបំណងចំបងនៃផែនការប្រើប្រាស់ដីនៅក្នុងឃុំប៉ុងនេះគឺដើម្បី គាំទ្រដល់ដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ កម្មវិធីវិនិយោគឃុំនិងសំរាប់ប្រើប្រាស់ក្នុងការរៀបចំអភិវឌ្ឍន៍ ឃុំទាំងមូលឱ្យមាននិរន្តរភាព ចំទិសដៅ និងឱ្យស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្រ និងគោលនយោបាយ វិមជ្ឈការ និង វិសហមជ្ឈការ សំដៅពង្រឹងអភិបាលកិច្ចល្អរបស់រាជរដ្ឋាភិបាល ដើម្បីលើកស្ទួយសេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង។

ក្រុមប្រឹក្សាឃុំប៉ុង សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ និងអង្គការ DANIDA/DFID-NZaid តាមរយៈស្ថានទូតដាណឺម៉ាក ប្រចាំនៅក្នុងប្រទេសកម្ពុជាដែលបានផ្តល់ថវិកាជំនួយ សំរាប់ដំណើរការរៀបចំផែនការប្រើប្រាស់ដីធ្លីនេះចាប់តាំងពីការចាប់ផ្តើមរហូតដល់ទីបញ្ចប់។

ជាមួយគ្នានេះដែរ ក៏សូមថ្លែងអំណរគុណផងដែរ ដល់ក្រុមការងាររបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្តរតនគីរី ដែលបានជួយសម្របសម្រួលក្នុងការរៀបចំផែនការនេះ ហើយផែនការប្រើប្រាស់ដីដែលបានលេចចេញជារូបរាងប្រកបដោយជោគជ័យនេះ ក៏ដោយសារតែមានការចូលរួម និងគាំទ្រពីសំណាក់មន្ទីរពាក់ព័ន្ធនានាជុំវិញខេត្ត ជាពិសេសគឺអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត រដ្ឋបាលព្រៃឈើ មន្ទីរកសិកម្ម និងមន្ទីរបរិស្ថានខេត្ត ។

ក្រុមប្រឹក្សាឃុំប៉ុងក៏មិនអាចបំភ្លេចបានផងដែរនូវការជួយឧបត្ថម្ភគាំទ្រ បង្ហាត់បង្ហាញទាំងទ្រឹស្តីនិងបច្ចេកទេសអនុវត្តផ្ទាល់លើការងាររៀបចំផែនការប្រើប្រាស់ដីធ្លី ពីក្រុមអ្នកសម្របសម្រួលរៀបចំផែនការប្រើ ប្រាស់ដីធ្លីថ្នាក់ខេត្ត ( P_LUP ) ថ្នាក់ស្រុក (D_LUP) និងក្រុមការងារថ្នាក់ជាតិ របស់សមាសភាគរៀបចំដែនដី។

យើងខ្ញុំទាំងអស់គ្នាសង្ឃឹមថា សម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ នឹងបានយល់ដឹងអំពី ស្ថានភាព និងតម្រូវការ ព្រមទាំងបញ្ហាប្រឈមទាំងឡាយពាក់ព័ន្ធនឹងការប្រើប្រាស់ដីធ្លី ដែលរាំងស្ទះដល់ដំណើរការអភិវឌ្ឍន៍ឃុំប៉ុងហើយ នឹងបង្ហាញនូវទឹកចិត្តសប្បុរសធម៌ដ៏ថ្លៃថ្លាតាមរយៈការចូលរួម ផ្តល់នូវសំភារៈ និង ថវិការសំរាប់គាំទ្រការអនុវត្តន៍ផែនការប្រើប្រាស់ដីធ្លីនេះ ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍ មូលដ្ឋានតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ របស់រាជរដ្ឋាភិបាលប្រកបដោយជោគជ័យ។

ឃុំប៉ុង,ថ្ងៃទី.05.....ខែ..04.....ឆ្នាំ ២០10

មេឃុំ ប៉ុង

គិ_ខាំ

## សេចក្តីផ្តើម

ឃុំប៉ុង ស្រុកវើនសៃ ខេត្តរតនគីរី ស្ថិតនៅតាមដងទន្លេសេសាន ប៉ែកខាងជើងមានចំងាយមួយគីឡូម៉ែត្រពីសាលាស្រុកវើនសៃ បើគិតពីខេត្តមកឃុំប៉ុងមានចំងាយសែសិបពីរគីឡូម៉ែត្រ ។ ហើយឃុំនេះបើពិនិត្យជាក់ស្តែងនៅទិសខាងកើតឃើញមានភ្នំមួយដែលលាតសន្ធឹងទទឹងថ្ងៃ ពីទិសខាងជើងទៅទិសខាងត្បូង។ ដោយស្ថានភាពអំណោយផល ឃុំប៉ុងភាគច្រើនប្រជាជនប្រកបមុខរបរកសិកម្ម ដូចជា ដាំកូនឈើ នេសាទ ដំណាំបូបផ្លែ និងដំណាំផ្សេង ៗ ទៀត និងការចញ្ចឹមសត្វ រកអនុផលព្រៃឈើជាដើម ។

ដោយពិនិត្យឃើញថា ឃុំប៉ុង មិនទាន់មានការគ្រប់គ្រងដី និង ធនធានធម្មជាតិពុំទាន់ច្បាស់លាស់ជាហេតុធ្វើអោយក្រុមប្រឹក្សាឃុំ និងសមាជិក គ.ផ.ថ ប្រជាជនក្នុងឃុំមានគោលបំណងបង្កើតផែនការប្រើប្រាស់ដីឃុំ មួយប្រកបដោយចីរភាព តម្លាភាព និង ប្រសិទ្ធភាពខ្ពស់ ។

ផែនការប្រើប្រាស់ដីបើនិយាយជារួមបានឆ្លុះបញ្ចាំងពីបញ្ហា និង តំរូវការចាំបាច់របស់ប្រជាពលរដ្ឋលើវិស័យទាំងប្រាំ ដូចជាសេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិ និងបរិស្ថាន ផ្នែកសេវាកម្មរដ្ឋបាល និង សន្តិសុខ ផ្នែកយេនឌ័រ ដើម្បីឆ្លើយតបទៅ នឹងសេចក្តីត្រូវការជាអទិភាពទាំងនេះក្នុងការចូលរួមចំនែកលើកកំពស់ជីវភាពរស់នៅ និងសុខភាពរបស់ប្រជាពលរដ្ឋអោយកាន់តែល្អប្រសើរឡើងជាងមុនបើនិយាយជារួមវិញផែនការប្រើប្រាស់ដីឃុំជា ឧបករណ៍មួយដ៏សំខាន់ ដែលជួយដល់ក្រុមប្រឹក្សាឃុំក៏ដូចជាខេត្តទាំងអស់នៅថ្នាក់ក្រោមជាតិក្នុងការចូលរួមចំណែកដល់ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិ ប្រកបដោយចិរភាព និងប្រសិទ្ធភាព ។ ដូចច្នេះការប្រើប្រាស់ដីឃុំជាការងារស្នូលសំរាប់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ពិសេសអាជ្ញាធរដែនដី និង មានមូលដ្ឋានអោយកាន់តែគ្រប់ជ្រុងជ្រោយក្នុងការរៀបចំបញ្ចូលផែនការប្រើប្រាស់ដី ទៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅថ្នាក់មូលដ្ឋានដោយធ្វើសមាហរកម្មផែនការថ្នាក់ស្រុក និង ការអនុម័តក្នុងការកសាងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការចូលរួមសេដ្ឋកិច្ច។

# ជំពូក ១

# ពត៌មាន និងទិន្នន័យសម្រាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំសន្ទាត់

## ១.១ ស្ថានភាពទូទៅ

ឃុំប៉ុងបានកកើតឡើងក្នុងឆ្នាំ ១៩៨២ ជាឃុំមួយក្នុងស្រុកវើនសៃ ខេត្តរតនគីរី។ ឃុំប៉ុង អ្នកភូមិច្រើន ទម្លាប់ហៅថា *បានប៉ុង* តាមសំនៀងដែលជាភាសាឡាវ ពាក្យថា*បាន* ភាសាឡាវមានន័យថា ភូមិ គឺភូមិប៉ុង ។ដោយពីមុនមកនៅទីនោះមានអូរមួយដែល មានឈ្មោះថាអូរប៉ុង ហើយភូមិដែល បានកកើតឡើងនៅទីនោះក៏មានឈ្មោះថាភូមិអូរប៉ុងដែរ ក្រោយមកហៅកាត់ថាភូមិប៉ុង តែដោយសារនៅទីនោះមាន បងប្អូនជានជាតិឡាវចេញចូលរកទទួលទានច្រើន ខ្មែរយើងក៏បានប្រើពាក្យ *បានប៉ុង* ដើម្បីឱ្យបកប្រែឱ្យជនជាតិឡាវងាយយល់ ហើយក៏បានប្រើត១ មករត់មាត់ថាដូច្នេះទៅ។

### ១.១.១ ទីតាំងរដ្ឋបាល

| | | |
|---|---|---|
| **ខេត្ត** | រតនគីរី | |
| **ស្រុក** | វើនសៃ | |
| **ឃុំ** | **ឈ្មោះ:** ប៉ុង | **លេខកូដ:** ១៦០៩០១ |
| **ចំនួនភូមិ** | **២ ភូមិ ក្នុងនោះមាន :** បានហ្វាំង ,បានប៉ុង | |

ឃុំប៉ុងជាឃុំស្ថិតនៅតាមដងទន្លេសេសាន្ត ស្ថិតនៅក្នុងស្រុកវើនសៃមានចំងាយមួយគីឡូម៉ែត្រខាងជើងសាលាស្រុកវើនសៃ បើគិតពីខេត្តមកឃុំប៉ុងមានចំងាយ ៤២ គីឡូមែត្រនាទិសពាយ័ព្យនៃទីរួមខេត្ត ។ ឃុំនេះមានព្រំប្រទល់ខាងជើងទល់នឹងទន្លេសេសាន្ត ខាងលិចទល់នឹងឃុំកាចូន ខាងត្បូងទល់នឹងឃុំកាឡៃ ខាងកើតទល់នឹងឃុំភ្នំកុក។ ឃុំនេះមានផ្ទៃក្រឡាទំហំ **៧ ០៨៥ ហិកតា** ចែកចេញជា២ភូមិ គឺភូមិប៉ុង និងភូមិហ្វាំង។




រូបភាព១:ផែនទីតាំងរដ្ឋបាល

### ១.១.២ ប្រជាសាស្ត្រ

ឃុំប៉ុងមានប្រជាជនសរុបចំនួន ២ ៥២៦នាក់ ក្នុងនោះស្រី ១ ៣៧០នាក់ ដង់ស៊ីតេប្រជាជនមាន ៣៥នាក់ ក្នុងមួយគីឡូម៉ែត្រក្រឡា ។ របាយប្រជាជនភាគច្រើនគឺប្រមូលផ្តុំនៅតាមដងទន្លេសេសាន្តចំណែកផ្នែកខាងត្បូង គឺពុំមានប្រជាជនកុះករទេ តែក៏មានការតាំងទីជាការប្រមូលផ្តុំរស់នៅតាមរដូវកាលសំរាប់ការធ្វើកសិកម្ម(តាមខ្ទមចាំចំការ)បន្តិចបន្តួចតែប៉ុណ្ណោះ។ ប្រជាជននៅក្នុងឃុំប៉ុងភាគច្រើនជាជនជាតិខ្មែរ និងជនជាតិឡាវដែលសុទ្ធសឹងជាអ្នករស់នៅទីនោះតាំងតែពីឆ្នាំ ១៩៧៩មក ដោយឡែកជនជាតិភាគតិច (ទំពួន) ដែលមានវត្តមាននៅក្នុងតំបន់នេះគឺមានតិចតួចគឺមានប្រមាណជា ១% តែប៉ុណ្ណោះ។ តែក្នុងមួយ រយៈពេលចុងក្រោយនេះ យើងសង្កេតឃើញមានការហូរចូលប្រជាជនមកពីខេត្តក្រៅ មកតាំងទីលំនៅក្នុង តំបន់នេះដែលមានចំនួនគួរឱ្យកត់ សំគាល់គឺ ប្រមាណជា ២០% ដែលភាគច្រើនមកពីខេត្ត កំពង់ចាម ក្រចេះ តាកែវ និងព្រៃវែង។ លើកំណើនដដែលនេះ ក៏មានការកត់សំគាល់ទៅលើការថយចុះនៃអត្រាមរណៈរបស់ កុមារផងដែរ។ ចំពោះជំនឿសាសនាប្រជាជននៅក្នុងឃុំ គឺមានលក្ខណៈដូចគ្នាទៅនឹងប្រជាជនក្នុងទីរួមខេត្ត ដែរគឺកាន់ព្រះពុទ្ធសាសនា ហើយនៅក្នុងឃុំក៏មានវត្តអារាមដែរ តែទោះជាយ៉ាងនេះក្តី ការសែនព្រេន និងជំនឿលើអារក្ខអ្នកតា ក៏នៅតែមានទៅតាមទម្លាប់របស់គេ។

<u>តារាងស្ថិតិប្រជាជនឃុំប៉ុង ឆ្នាំ២០០៨ តាមក្រុមអាយុ</u>

| ស្ថិតិតាមក្រុមអាយុ | ប្រុស | ស្រី | សរុប | ផ្សេងៗ |
|---|---|---|---|---|
| អាយុក្រោម០៥ឆ្នាំ | ១៦១ | ១៦៤ | ៣២៥ | |
| អាយុ ០៥ឆ្នាំ | ៦៤ | ៦៣ | ១២៧ | អាយុចូលរៀនមត្តេយ្យ |
| អាយុពី ៦-១១ឆ្នាំ | ២០១ | ២៣៣ | ៤៣៤ | អាយុចូលរៀនបឋមសិក្សា |
| អាយុពី ១២-១៤ឆ្នាំ | ៩៨ | ១៤៤ | ២៤២ | អាយុចូលរៀនអនុវិទ្យាល័យ |
| អាយុពី ១៥-១៧ឆ្នាំ | ១១៥ | ១៣០ | ២៤៥ | អាយុចូលរៀនវិទ្យាល័យ |
| អាយុពី ១៨-២៤ឆ្នាំ | ១៤០ | ១៥៨ | ២៩៨ | អាយុចូលរៀនមហាវិទ្យាល័យ |
| អាយុពី ២៥-៦០ឆ្នាំ | ៣៤៣ | ៤១៦ | ៧៥៩ | អាយុពេញពលកម្ម |
| អាយុពី ៦១ឆ្នាំឡើងទៅ | ៣៤ | ៦២ | ៩៦ | អាយុចូលនិវត្តន៍ |
| ប្រជាជនសរុប | ១១៥៦ | ១៣៧០ | ២៥២៦ | |
| **ចំនួនគ្រួសារសរុប** | **៤៦៧** | | | |

### ១.១.៣ ភាពគ្មានដីធ្លី

កង្វះខាត ឬភាពគ្មានដីធ្លី នៅក្នុងឃុំប៉ុងហាក់ដូចជាមិនទាន់កើតមានជាបញ្ហាចោទខ្លាំងនៅឡើយទេ បើទោះបី ៨៨% នៃប្រជាជនជាកសិករក៏ដោយ ក៏ពួកគាត់នៅតែមានការពឹងពាក់យ៉ាងខ្លាំងទៅលើធនធានធម្មជាតិ ហើយស្ទើរតែជាង ៥0% នៃគ្រួសារទាំងអស់ត្រូវទិញស្រូវបន្ថែមសំរាប់ការបរិភោគប្រចាំឆ្នាំ ដោយប្រើប្រាស់ចំណូលដែលរកបានពីធនធានព្រៃឈើ និងជលផល។ នេះមិនមែនជាបញ្ហាក្នុងការខ្វះខាតដីធ្លីទេ តែវាមកពីការធ្វើកសិកម្មយថាផលដែលមានទិន្នផលទាប និងប្រពៃណី ទម្លៀមទម្លាប់ក្នុងការរកទទួលទានរបស់ពួកគាត់ពីដើមមក។ តែទោះបីយ៉ាងណាក៏ដោយក៏នៅមានគ្រួសារប្រមាណជាង ៦៤គ្រួសារទៀតដែរដែល ពួកគាត់គ្មានដីធ្វើស្រែ ហើយអ្នកដែលគ្មានដីស្រែទាំងនោះ ពួកគាត់ត្រូវបានជួលដីស្រែគេធ្វើ ពេលបានផលពួគគាត់ត្រូវសងអោយអ្នកម្ចាស់ដីក្នុង១ស្រែ ៦ហាបបើគិតជាគីឡូក្រាម ១ហាប ស្មើនឹង ៦0 គីឡូក្រាមក្រៅពីមុខរបរជួលស្រែគេ ពួកគាត់រកស៊ីស្មូលបេះគ្រាប់ចន្ទី ជំរះស្មៅសណ្តែកសៀង រកអនុផលព្រៃឈើ អាឈើលក់ និងនេសាទត្រី ។



រូបភាព២: គ្រួសារគ្មានដីលំនៅដ្ឋាន

តារាងចំនួនគ្រួសារដែលគ្មានដី និងមានដីមិនគ្រប់គ្រាន់

| លរ | បរិយាយ | ចំនួនគ្រួសារ | ភាគរយ/ប្រជ.សរុប | ផ្សេងៗ |
|---|---|---|---|---|
| ១ | គ្មានដីស្រែផ្ទាល់ខ្លួន | ៩៨ | ២៤.២០% | |
| ២ | មានដីស្រែតិចជាង ១ ហិកតា | ៣២ | ៧.៩០% | |
| ៣ | គ្មានដីលំនៅដ្ឋាន | ១០១ | ២១.៦៣% | |

**ប្រភព:** ឯកសារពតិមានស្តីពីស្ថានភាពឃុំប៉ុង ឆ្នាំ ២០០៩

## ១.១.៤ ស្ថានភាពសេដ្ឋកិច្ច

ប្រជាជនឃុំប៉ុងមាន ៨៨% ប្រកបរបរកសិកម្ម ដូចជាធ្វើស្រែ ចំការ ក្រៅពីការងារស្រែ ចំការ ពួកគាត់តែងតែឆ្លៀតឱកាស នេសាទត្រី បរបាញ់សត្វ ស៊ីឈ្នួល ចិញ្ចឹមសត្វ ធ្វើសួនបន្លែតាមគ្រួសារ ដោយដាំដំណាំហូបផ្លែ និង បន្លែបង្កាផ្សេងៗទៀត ហើយផលិតផលដែលគាត់ផលិតបានពួកគាត់ទុកសំរាប់ធ្វើជាអាហារ និងមួយចំនួនទៀតយកទៅលក់ឬដោះដូរជា របស់របរផ្សេងៗតែមុខរបរកសិកម្មនេះមិនមែនជារបរដែលគាត់មានការពឹងផ្អែកទាំងស្រុងទៅលើនោះទេ ក្នុងចំណោមកសិករទាំងអស់មានតែ៤៥%តែប៉ុណ្ណោះដែលមានស្រូវគ្រប់គ្រាន់សំរាប់ទទួលទានរយៈពេលពេញមួយឆ្នាំ។ ប្រជាជនភាគច្រើនធ្វើស្រែវស្សា ៣៥%នៃចំនួនគ្រួសារ កសិករនៅធ្វើកសិកម្មពនេចរនៅឡើយទិន្នផលស្រូវជាធម្យមទាប គឺទទួលបានប្រមាណជា ១,៥០តោន ក្នុងមួយហិកតា។

ក្រៅពីកសិកម្មប្រជាជនមានការពឹងពាក់ទៅលើព្រៃឈើ និងនេសាទដូចជាការ បោចវល្លិ៍ ផ្តៅ ជ័រទឹក ជ័រចុងផ្សិត និងបន្លែបង្ការព្រៃ រុករកចាប់សត្វដូចជា អណ្តើក ត្រកួត និងការនេសាទត្រី។ លើសពីនេះក៏នៅមានឈើសំណង់ដែលផ្គត់ផ្គង់សំរាប់ការសាងសង់សំណង់ផ្សេងៗក្នុងទីរួមខេត្តទៀតផង។

តារាងមុខរបបរសំខាន់ៗរបស់ប្រជាជនឃុំ

| ល.រ | ប្រភេទមុខរបបរ | ចំនួនគ្រួសារ | | ផ្សេងៗ |
|---|---|---|---|---|
| | | ចំនួន | ភាគរយ (%) | |
| ១ | មុរបរកសិកម្ម | | | |
| | ធ្វើស្រែជាចំបង | ៤០៥ | ៨៦.៧២% | |
| | ដាំដំណាំរយៈពេលវែងជាចំបង | ៣ | ០.៦៤% | |
| | ដាំដំណាំរយៈពេលខ្លីជាចំបង | ១ | ០.២១% | |
| | ដាំដំណាំបន្លែជាចំបង | ១ | ០.២១% | |
| | នេសាទត្រី | ១ | ០.២១% | |

**ប្រភព** : ឯកសារពតិមានស្តីពីស្ថានភាពឃុំប៉ុង ឆ្នាំ ២០០៩

## ១.១.៥ ស្ថានភាពអប់រំ និងសិក្សាធិការ

ឃុំប៉ុងមានកំរិតនៃការសិក្សាដល់អនុវិទ្យាល័យ មានសាលារៀនចំនួន ១ ដែលមាន ៥ បន្ទប់ ស្មើនឹង ៤ ថ្នាក់ មាន គ្រូបង្រៀនចំនួន ៦ នាក់ដែលមានសិស្សអនុវិទ្យាល័យ ១៧៩ នាក់ ក្នុងនោះសិស្សស្រី ៩៥ នាក់ ចំពោះសិស្សដែល មិន បានចូលរៀនចំនួន ៦៣ នាក់ ត្រូវជា ២៦.០៣% ។ ដោយឡែកថ្នាក់បឋមសិក្សាមានសាលារៀន ចំនួន ០៣ មាន ១៤ បន្ទប់ ស្មើនឹង ១៥ ថ្នាក់ដែលមានគ្រូបង្រៀនចំនួន ១០ នាក់ សិស្សដែលបានចូលរៀន ២៧៧នាក់ ក្នុងនោះសិស្ស ស្រី ១៣៦ នាក់ ។ ចំពោះមត្តេយ្យសិក្សាវិញពុំមានសាលានោះទេ កុមារសរុបមានចំនួន ១២៧នាក់ តែពុំបានចូលរៀន ទេ។ កុមារគ្រប់អាយុដែលត្រូវចូលរៀនសរុបមាន ១៥នាក់ក្នុងនោះមានស្រី ០៥ នាក់។ បើតាម ការពិនិត្យ ជាក់ស្តែង ក្នុងឃុំនេះមានការខ្វះខាតថ្នាក់រៀនចំពោះតែថ្នាក់បឋមសិក្សា និងមធ្យមសិក្សា រីឯអត្រាសិស្សមិនបានចូលរៀននេះ គឺមកពី :

- បញ្ហា ខ្វះគ្រូបង្រៀន បឋមសិក្សា
- ដោយឡែកចំពោះសិស្សដែលបានបញ្ចប់ការសិក្សា ពីថ្នាក់អនុវិទ្យាល័យនៅឃុំប៉ុងនោះមានចំនួន៩០នាក់ ត្រូវជួបបញ្ហា ដោយសិស្សត្រូវបន្តទៅរៀននៅវិទ្យាល័យនៅទីរួមខេត្តដែលមានចំងាយផ្លូវជាង ៤២ គ.ម ដូច្នេះចំពោះសិស្សដែលក្រីក្រត្រូវបោះបង់ចោលការសិក្សា។ សាលារៀននៅឃុំប៉ុងបច្ចុប្បន្នភាគច្រើន ជាអាគារធ្វើពីថ្មចាក់បេតុង ដែលមានការឧបត្ថម្ភពីអង្គការក្រៅរដ្ឋាភិបាល និង រដ្ឋាភិបាល ។

<u>តារាងស្ថិតិសាលា និងចំនួនសិស្ស ប្រចាំឆ្នាំ ២០០៨</u>

| ប្រភេទសាលា | ចំនួនសាលានៅឆ្នាំ ២០០៨ | | | ចំនួនកុមារ/សិស្សនៅឆ្នាំ ២០០៨ | | | អត្រាមិនចូលរៀន |
|---|---|---|---|---|---|---|---|
| | សាលា | បន្ទប់ | ថ្នាក់ | កុមារសរុប | សិស្សសរុប | សិស្សស្រី | |
| ថ្នាក់មត្តេយសិក្សា | ០ | ០ | ០ | ១២៧ | ០ | ០ | ១០០% |
| ថ្នាក់បឋមសិក្សា | ៣ | ១៤ | ១៥ | ៤៣៤ | ២៧៧ | ១៣៦ | ៣៦% |
| ថ្នាក់អនុវិទ្យាល័យ | ១ | ៥ | ៤ | ២៤២ | ១៧៩ | ៩៥ | ២៦% |
| ថ្នាក់វិទ្យាល័យ | ០ | ០ | ០ | ២៤៥ | ៩០ | - | ៦៣% |
| ... | | | | | | | |

**<u>ប្រភព:</u>** ឯកសារពត៌មានស្តីពីស្ថានភាពឃុំប៉ុង ឆ្នាំ ២០០៩



រូបភាព៣:សាលារៀនឃុំប៉ុង

## ១.១.៦ ស្ថានភាពសុខាភិបាល

### ១.១.៦.១ ផ្នែកសុខាភិបាល

ឃុំប៉ុងមានសេវាសុខភាព ១កន្លែង ស្ថិតនៅក្បែរសាលាស្រុកវ៉ារិនសៃ បើគិតពីចំងាយផ្លូវពីភូមិប៉ុងមក មណ្ឌលសុខភាពមានចំងាយ ១.៥គីឡូម៉ែត្រ នឹងពីភូមិបានហ្វាំង មកមណ្ឌលសុខភាពមានចំងាយ ២គីឡូម៉ែត្រ បច្ចុប្បន្នមណ្ឌលសុខភាព នោះមានគ្រូពេទ្យចំនួន ១០នាក់ ដោយឡែកឃុំប៉ុងក៏មានគ្រូពេទ្យបុរាណនៅតាមភូមិមួយចំនួន ៤ នាក់ដែរ ។ ចំពោះសេវាសុខភាពនៅក្នុងឃុំនេះពុំទាន់បានបំពេញនៅសេចក្ដីត្រូវការរបស់ប្រជាជនទូទាំងឃុំនៅឡើយព្រោះមិនមានគ្រូពេទ្យប្រចាំការសំរាប់ថែទាំសុខភាពគ្រប់គ្រាន់នៅឡើយម៉្យាងទៀត គ្រូពេទ្យដែលបំរើការងារសព្វថ្ងៃ មានជំនាញមានកំរិត រីឯសេវាផ្សព្វផ្សាយពីការថែទាំសុខភាពមិនទាន់បានទូលំទូលាយ កត្តានេះហើយបានធ្វើអោយប្រជាជនមួយចំនួនគាត់មិនបានទៅសេវាសុខភាពទេ ។អ្នកភូមិមួយចំនួននៅពេលគាត់មានជំងឺធ្ងន់ធ្ងរពួកគាត់តែងតែមានការកាប់ជ្រូក ឬមាន់ ដើម្បីសែនព្រេន អ្នកភូមិខ្លះទៀតក៏មកព្យាបាលនៅពេទ្យខេត្តដែលមានចំងាយផ្លូវ ៤២ គីឡូ ម៉ែត្រ និង ពិបាកក្នុងការធ្វើដំណើរ ។

ផ្អែកទៅតាមស្ថានភាពភូមិសាស្ត្រនៃឃុំប៉ុង ដែលមានប្រជាជនរស់នៅតាមភូមិដាច់ឆ្ងាយពីគ្នា និងមានចំងាយផ្លូវឆ្ងាយពីមណ្ឌលសុខភាពឃុំបណ្តាលអោយមានការលំបាកក្នុងការធ្វើដំណើរដូច្នេះ ការផ្តល់សេវាកម្ម ផ្នែកសុខភាពមិនទាន់គ្រាប់គ្រាន់ ។ ស្ថិតក្នុងដំណាក់កាលនេះឃុំប៉ុង ក៏ពុំទាន់មាន ប៉ុស្តិ៍សុខភាព នៅតាមភូមិ សំរាប់ជួយសំរួលដល់ការទ្រទ្រង់ សុខមាលភាព របស់ប្រជាពលរដ្ឋ បន្ថែមលើមណ្ឌលសុខភាពនៅឡើយទេ ។

តារាងស្ថិតិមណ្ឌល/ប៉ុស្តសុខភាព និងចំនួនគ្រូពេទ្យ

| ល.រ | មណ្ឌល/ប៉ុស្តិ៍សុខភាព | សមត្ថភាពផ្គត់ផ្គង់សេវាកម្ម | | | | |
|---|---|---|---|---|---|---|
| | | ចំនួន | គ្រែ/បន្ទប់ | គ្រូពេទ្យ | ពេទ្យឆ្មប | ឆ្មបបុរាណ |
| ១ | មណ្ឌលសុខភាព | ០១ | ៣ | ១០ | ២ | ៤ |
| ២ | ប៉ុស្តិ៍សុខភាពភូមិ | 0 | 0 | 0 | 0 | 0 |

ប្រភព: ឯកសារពត៌មានស្តីពីស្ថានភាពឃុំប៉ុង ឆ្នាំ ២០០៩




**រូបភាព៣៤:** មណ្ឌលសុខភាពឃុំប៉ុង

### ១.១.៦.២ ការផ្គត់ផ្គង់ទឹកស្អាត

ចំពោះសេវានៃការប្រើប្រាស់ទឹកស្អាតប្រជាជននៅក្នុងឃុំប៉ុងមានអណ្តូងទឹក ចំនួន ៤២ អណ្តូង និង អណ្តូងស្នប់ចំនួនបី ដែលឧបត្ថម្ភដោយអង្គការក្រៅរដ្ឋាភិបាល ហើយបើគិតទៅលើគ្រួសារដែលបានប្រើទឹកអណ្តូង មានចំនួនតែ ៧៧ គ្រួសារប៉ុណ្ណោះ ដូចនេះ ប្រជាជន ៣៩០គ្រួសារទៀត មិនបានប្រើប្រាស់ទឹកអណ្តូងទេ តែពួគាត់ ប្រើប្រាស់ទឹកទន្លេសេសាន ជំនួសវិញ  រីឯការប្រើប្រាស់បង្គន់អនាម័យប្រជាជនឃុំប៉ុង មានបង្គន់អនាម័យចំនួន១០៥ គ្រួសារ ចំណែកគ្រួសារ ៣៦២ ទៀតមិនមិនទាន់មានបង្គន់អនាម័យក្នុងឃុំគ្រប់គ្រាន់ទេ ដូចនេះធ្វើអោយប្រជាជនខ្លះគាត់តែងតែមានជំងឺរាករូសខ្លាំងដែរ ។

<u>តារាងស្ថិតិប្រភពទឹកប្រើប្រាស់នៅក្នុងឃុំ ប៉ុង</u>

| ល.រ | ប្រភពទឹកស្អាត | ចំនួនប្រភពទឹក | | | សំគាល់ |
|---|---|---|---|---|---|
| | | សរុប | ប្រើបាន | ខូចខាត | |
| ១ | អណ្តូងស្នប់ | ៣ | ៣ | ០ | ខូចត្រូវជួសជុលឡើងវិញ |
| ២ | អណ្តូងលូ | ៤២ | ៤២ | ០ | ខូចត្រូវស្តារឡើងវិញ |

**<u>ប្រភព:</u>** ឯកសារពតិមានស្តីពីស្ថានភាពឃុំប៉ុង ឆ្នាំ ២០០៩



រូបភាព៩:អណ្តូងដៃឃុំប៉ុង

## ១.២. ស្ថានភាពភូមិសាស្ត្រ

### ១.២.១ ទីតាំងភូមិសាស្ត្រ

ភូមិសាស្ត្រឃុំប៉ុងមានរាងទ្រវែង បណ្តោយប្រមាណជា ១៦ គម. និងទទឹងប្រមាណជា ៤គម. បញ្ឆិតលាតសន្ធឹងយ៉ាងវែងតាមទិសដៅពីទិសពាយ័ព្យមកទិសអគ្នេយ៍ ផ្នែកខាងជើងនៃឃុំស្ថិតនៅជាប់នឹងដងទន្លេសេសានផ្ទៃដី ឃុំទាំងមូលតំបន់នេះជាតំបន់ខ្ពង់រាប ដែលផ្នែកខាងជើងជាប់នឹងទន្លេមានរយៈ កំពស់ពី ១០២ម. ដល់ ១៣៨ម. រហូតស្ទើរតែមកដល់ពាក់កណ្តាលនៃឃុំ បន្តមកមានរយៈកំពស់ពី ១៣៨ម. ដល់ ២១៦ម. ហើយភាគខាងត្បូងជាតំបន់កូនភ្នំ ដែលអាចមានរយៈកំពស់ពី ២១៦ម. រហូតដល់ ៤០២ម.។ ដោយសារតំបន់ភាគ ខាងត្បូងជា តំបន់កូនភ្នំ តំបន់នេះមានលក្ខណៈជាទីជំរាល ដែលមានផ្លូវទឹកយ៉ាងខ្វាត់ខ្វែងតែភាគច្រើន មានទឹកហូរខ្លាំងតែនៅរដូវវស្សាទឹកនេះ ប្រមូលផ្តុំហូរចាក់ចូលមកទន្លេសេសាន។




**រូបភាព៧** :ផែនទីរយៈកំពស់ប៉ុង

### ១.២.២ អាកាសធាតុ

-ជាទូទៅខេត្តរតនគិរីមានកំពស់ទឹកភ្លៀងអតិបរិមាជាមធ្យមពី ២១១៩.៨ម.ម ទៅ ២៧៩១.៧ម.ម និង កំពស់អប្បបរិមាពី ៤៨៣.៤ម.មទៅ ៦៩៨.៧ម.ម និយាយជារួម និងដោយឡែកសំរាប់ឃុំប៉ុង កំពស់ទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំមាន ២៩០,២០មម.។

-បើនិយាយពីរដូវ រយៈពេលនៃរដូវប្រាំងគឺមានរយៈពេល ៦ខែ គឺពីខែវិច្ឆិកាដល់ខែមេសា និងរយៈពេលនៃរដូវវស្សាមានរយៈពេល៦ខែ គឺពីខែឧសភាដល់ខែតុលា សំរាប់ខេត្តរតនគិរី តែបើនិយាយចំពោះឃុំប៉ុងគឺមានភ្លៀងធ្លាក់ចាប់ពីខែឧសភារហូតដល់ខែវិច្ឆិកាជារៀងរាល់ឆ្នាំគឺមានរយៈពេល៧ខែ។

-សីតុណ្ហភាពអតិបរមាពី ៣៤.៧អង្សាសេ ដល់ ៣៨.៨.អង្សាសេ និងអប្បរមាពី ១៨.៩អង្សាសេ ទៅ ២១.៥ អង្សាសេ និយាយជារួមសំរាប់ខេត្តរតនគិរី ចំពោះឃុំប៉ុងអាចត្រជាក់ជាងនេះព្រោះជាតំបន់គ្របដណ្តប់ដោយព្រៃឈើ ហើយស្ថិតនៅជាប់ទន្លេ។




| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| " 2003" | 0.0 | 0.0 | 90.8 | 121.0 | 390.2 | 287.1 | 480.3 | 396.6 | 452.7 | 77.6 | 55.6 | 0.0 |
| " 2004" | 0.0 | 0.0 | 48.6 | 23.8 | 172.0 | 511.1 | 413.8 | 509.4 | 400.5 | 32.6 | 8.0 | 0.0 |
| "2005" | 0.0 | 0.0 | 6.4 | 48.8 | 195.7 | 300.9 | 643.6 | 746.7 | 408.5 | 128.4 | 13.6 | 7.4 |
| " 2006" | 0.0 | 0.0 | 0.0 | 147.2 | 317.6 | 212.2 | 682.9 | 642.0 | 504.5 | 257.6 | 0.0 | 27.7 |

### ១.២.៣ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន

ភូមិសាស្ត្រឃុំប៉ុងស្ថិតនៅជាប់ទន្លេសេសាន ដែលជាផ្នែកមួយនៃផ្លូវទឹកអំណោយផលដល់ប្រជាជនក្នុងការធ្វើដំណើរក៏ដូចជាក្នុងការដឹកជញ្ជូនដែរតែស្ថានភាពទន្លេមិនអំណោយផលឱ្យទូកកាណូតធំៗចេញចូលបានទេ ទូកដែលអាចធ្វើចរាចរបានតាមដងទន្លេ នេះគឺអាចដឹក បានត្រឹមតែចំណុះ ៣តោនតែប៉ុណ្ណោះ ការធ្វើដំណើរ និងការដឹក ជញ្ជូនតាមផ្លូវទឹកភាគច្រើនគឺតភ្ជាប់ពីឃុំទៅកាន់ខេត្តស្ទឹងត្រែង។

ចំណែកផ្លូវគោកគឺមានផ្លូវក្រាលគ្រួសក្រហមចំនួន ២ខ្សែ ខ្សែទី១ គឺផ្លូវបំបែកពីផ្លូវតភ្ជាប់ពីខេត្តទៅស្រុកវើនសៃទៅកាចូន និងផ្លូវតភ្ជាប់ពីស្រុកទៅដល់ឃុំប៉ុង ហើយនិងផ្លូវក្រាលគ្រួសក្រហមតូចៗជាច្រើនខ្សែទៀតដែលមានប្រវែងសរុប៣៧,៣៨គ.មសំរាប់ការធ្វើដំណើររបស់ប្រជាជននៅក្នុងឃុំរីឯផ្លូវថ្មីជើងឬផ្លូវរទេះគឺជាផ្លូវចូលភូមិផ្សេងៗ

មានជាច្រើនខ្សែដែលមានប្រវែងសរុបទាំងអស់៣៣,៣៧គម ។   ផ្លូវគ្រួសក្រហមនេះត្រូវបានតភ្ជាប់គ្នាដោយស្ពានឈើចំនួន៧កន្លែង និងលូឆ្លងផ្លូវចំនួន១០លូ ។



**រូបភាព៣៨:**ផ្លូវក្រាលគ្រួសក្រហមឃុំប៉ុង

# ១.៣ ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

## ១.៣.១ ស្ថានភាពនៃការប្រើប្រាស់ដី

ក្នុងឃុំប៉ុងមានចំណាត់ថ្នាក់នៃការប្រើប្រាស់ដីលំអិតចំនួន១៧ប្រភេទរួមមានដីលំនៅដ្ឋានភូមិ( ផ្ទះ-ឈើហូបផ្លែ) កន្លែងកប់ខ្មោច(ដីកន្លែងកប់ខ្មោច) ស្រូវវស្សា ដីកសិកម្មពនេចរ ( ដីចំការផ្លាស់វេន ) ព្រៃស្រោងស្ងួត ( ព្រៃញាតមានឈើធំៗ) ព្រៃល្បោះ  ព្រៃល្បោះស្ងួតព្រៃចំរុះ( ស្រោង  និងរបោះ) ព្រៃដុះឡើងវិញ( ព្រៃកម្ពោធ)វាលស្មៅ  (ស្រែបោះបង់) ចំការបោះបង់ដុះស្មៅ ( ព្រៃឫស) ព្រៃគម្ពោធ ចំការបោះបង់ដុះព្រៃគម្ពោធព្រៃគម្ពោធ លាយដើមឈើ ធំមួយៗ បឹង អូរ-ស្ទឹង-ទន្លេ  វាលភក់និងប្រភេទនៃការប្រើប្រាស់ដីសាមញ្ញ ៦ ប្រភេទរួមមាន ដីលំនៅដ្ឋានភូមិ ( ផ្ទះ-ឈើហូប

ផ្លែ) កន្លែងកប់ខ្មោច (ដីកន្លែងកប់ខ្មោច) ដីកសិកម្ម ( ដីចំការ ) ព្រៃឈើ វាលស្មៅ វាលស្បូវ ប្រភពទឹក ដីដែលគ្មានរុក្ខជាតិដុះគ្រប ដណ្តប់ ។

<u>តារាងប្រភេទនៃការប្រើប្រាស់ដីលំអិត</u>

| លរ | ប្រភេទនៃការប្រើប្រាស់ដី | ក្រឡាផ្ទៃ | | ចំណាត់ថ្នាក់របស់មូលដ្ឋាន |
|---|---|---|---|---|
| | | ម² ម៉ែត្រក្រឡា | ហិចតា | |
| ១ | ដីលំនៅដ្ឋានភូមិ | ៦៨៦៦៦៤.៧៩ | ៦៩ | ផ្ទះ-ឈើហូបផ្លែ |
| ២ | កន្លែងកប់ខ្មោច | ៧០៤៤៥.២៧ | ៧ | ដីសំរាប់កប់ខ្មោច |
| ៣ | ស្រូវវស្សា | ៨៤៨៤៨០៧.៧៦ | ៨៤៨ | ស្រូវវស្សា |
| ៤ | ដីកសិកម្មពនេចរ | ៤៦២១៦០៦.០៧ | ៤៦២ | ដីចំការផ្លាស់វេន |
| ៥ | ព្រៃស្រោងស្ងួត | ១០៧៩០៩៩៩.៥១ | ១០៧៩ | ព្រៃញាតមានឈើធំៗ |
| ៦ | ព្រៃល្បោះ | ៧២២០០០៣.៣០ | ៧២២ | ព្រៃល្បោះ |
| ៧ | ព្រៃល្បោះស្ងួត | ៨៧៩៩២.០៧ | ១០ | ព្រៃល្បោះស្ងួត |
| ៨ | ព្រៃចំរុះ( ស្រោង និងរបោះ) | ១៤២០២៦០១.២៥ | ១៤២០ | ព្រៃចំរុះ ( ស្រោង និងរបោះ) |
| ៩ | ព្រៃដុះឡើងវិញ | ២០៦៣០៣៧១.៥១ | ២០៦៣ | ព្រៃកម្ពោធ |
| ១០ | វាលស្មៅ | ៩៣៤៣៦.៩០ | ៩ | ស្រែបោះបង់ |
| ១១ | ចំការបោះបង់ដុះស្មៅ | ២២៥៤៣៣.៦៧ | ២៣ | ព្រៃបូស |
| ១២ | ព្រៃគម្ពោធ | ១៤៥២០៥១.២៧ | ១៤៥ | ព្រៃគម្ពោធ |
| ១៣ | ចំការបោះបង់ដុះព្រៃគម្ពោធ | ៩៨៨៧៦៨.៥៥ | ៩៩ | ចំការបោះបង់ដុះព្រៃគម្ពោធ |
| ១៤ | ព្រៃគម្ពោធលាយដើមឈើធំមួយៗ | ១១៤៤៦២៦.៤៩ | ១១៤ | ព្រៃគម្ពោធលាយដើមឈើធំមួយៗ |
| ១៥ | បឹង | ១០៣៩៥២.៣១ | ១០ | បឹង |
| ១៦ | អូរ-ស្ទឹង-ទន្លេ | ១៧៥៦.៤៧ | ០.១៨ | អូរ-ស្ទឹង-ទន្លេ |
| ១៧ | វាលភក់ | ៥៤៣១៩.៧៦ | ៥ | វាលភក់ |
| | **សរុប** | **៧០៨៥៩៣៩៦.៩៥** | **៧០៨៥** | |

<u>ប្រភព</u>: ទិន្នន័យភូមិសាស្ត្រធ្វើបច្ចុប្បន្នភាពថ្ងៃ២១ ខែឧសភា ឆ្នាំ២០០៩

### ១.៣.២ ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដី

ស្ថានភាពនៃការគ្រប់គ្រងនិងកាន់កាប់ដីក្នុងឃុំទាំងមូល គឺមានជាដីលំនៅដ្ឋាន ដីស្រែ ដីចំការពនេចរ ជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ ។ ក្រៅពីដីលំនៅដ្ឋាន ដីស្រែ ដីចំការ ស្ទើរតែទាំងអស់នៃផ្ទៃដីគឺជាដីសាធារណៈរបស់រដ្ឋ ។

**-សហគមន៍ព្រៃឈើប៉ុង:** ឃុំប៉ុងមានព្រៃសហគមន៍ចំនួន១កន្លែងគឺសហគមន៍ព្រៃឈើប៉ុងដែលមានផ្ទៃ៣៤៦ហិចតា ជាតំបន់សំបូរដោយធនធានឈើប្រណិត១និងជីវៈចំរុះច្រើនប្រភេទដែលមួយភាគ នៃប្រភេទព្រៃជាព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោងហើយដែលសហគមន៍នៅទីនោះធ្វើការការពារយ៉ាងតឹងតែង បំផុតក្នុងគោលបំណងរក្សាធនធានអោយនៅយូរអង្វែងដើម្បីធានាការប្រើប្រាស់មានប្រសិទ្ធិភាពនិងមាននិរន្តរភាព។ ក្រៅពីនោះមានព្រៃរបោះ និងព្រៃផ្សេងៗទៀតដែលអាចផ្តល់លទ្ធភាពអោយសត្វព្រៃជ្រកកោនរកចំណីអាហារ និងមនុស្សអាចទាញយកផល-អនុផលពីព្រៃទាំងនោះ ។សហគមន៍ព្រៃឈើប៉ុងត្រូវបានប្រជាពលរដ្ឋនៅក្នុងឃុំបង្កើតឡើងដើម្បីការពារ និងថែរក្សាទុកជាសម្បត្តិធម្មជាតិដ៏មានតំលៃទៅអនាគត ។សហគមន៍ព្រៃឈើនេះនៅមិនទាន់មានការទទួលស្គាល់ណាមួយតាមលំដាប់ថ្នាក់នៅឡើយទេ។

- តំបន់ការពារបឹងបានហ្វាំង

- ផ្នែកនៃទន្លេសេសាន

<u>តារាងសង្ខេបស្ថានភាពកាប់កាប់និងគ្រប់គ្រងដី</u>

| លរ | ប្រភេទនៃការគ្រប់គ្រង | ទំហំដី (ហត) | ផ្សេងៗ |
|---|---|---|---|
| ១ | សហគមន៍ព្រៃឈើប៉ុង | ៣៤៦ | សាធារណៈរបស់រដ្ឋ |
| | ចំការបោះបង់ដុះព្រៃគម្ពោធ | ១,២0 | ១កន្លែង |
| | ព្រៃស្រោងសើម | ៤,៨0 | ១កន្លែង |
| | ព្រៃចំរុះ(ស្រោងនិងរបោះ) | ២១២,00 | ១កន្លែង |
| | ព្រៃដុះឡើងវិញ | ៨៩,00 | ១កន្លែង |
| | ព្រៃគម្ពោធលាយដើមឈើធំមួយៗ | ៣៩,00 | ១កន្លែង |
| ២ | តំបន់ការពារបឹងបានហ្វាំង | - | សាធារណៈរបស់រដ្ឋ |
| ៣ | ផ្នែកនៃទន្លេសេសាន | ផ្ទៃទឹក | សាធារណៈរបស់រដ្ឋ |

## ១.៣.៣ ស្ថានភាពកសិកម្ម

ប្រជាជនឃុំប៉ុងចំនួន ៨៨% នៃចំនួនគ្រួសារដែលប្រកបរបរកសិកម្ម ៦៥% ធ្វើស្រែវស្សា និង ៣៥% ធ្វើកសិកម្មពនេចរ។ តំបន់ដីនេះជាតំបន់ដែលពុំសូវមានជីជាតិ ទិន្នផលស្រូវទាបគឺប្រមាណជា ១,៥0តោន ក្នុងមួយហិកតា ដោយឡែកកសិកម្មពនេចរ គឺធ្វើបានផលល្អប្រសើរតែក្នុងរយៈឆ្នាំទី១តែប៉ុណ្ណោះ ហើយដីនេះត្រូវបាន បោះបង់ចោលរហូតទៅដល់ខួបពី ៨ ដល់ ១០[១] ឆ្នាំទើបអាចវិលមកធ្វើកសិកម្មសារជាថ្មីលើដីនោះ។

[១] ខួបរយៈពេល ១០ឆ្នាំសំរាប់កសិកម្មពនេចរ គឺជាខួបមួយខ្លី ដែលការវិលជុំបែបនេះនឹងធ្វើឱ្យដីខ្សោះជីជាតិជាលំដាប់

តារាងប្រភេទដំណាំកសិកម្ម សំខាន់ៗ និងទិន្នផលទទួលបាន

| ល.រ | ប្រភេទកសិកម្ម | ផ្ទៃដី (ហត) | | ផល/ទិន្នផល | |
|---|---|---|---|---|---|
| | | សរុប(ហត) | ដាំបាន (ហត) | ផលសរុប(តោន) | ទិន្នផល(ត/ហត) |
| ១ | ដំណាំស្រូវវស្សា | ៨៤៨ | ៤០០ | ៥៥៥ | ១.៤ |
| ២ | ដំណាំស្រូវចំការ | ៤ | ៤ | ២ | ០.៥ |
| ៣ | ដំណាំសណ្តែកបាយ | ២ | ២ | ៤ | ២ |
| ៤ | ដំណាំដំឡូងមី | ២ | ២ | ២ | ១ |

ប្រភព: ឯកសារពតិមានស្តីពីស្ថានភាពឃុំប៉ុងឆ្នាំ ២០០៩ (ទិន្នផលស្រូវមធ្យម០១ឆ្នាំចុងក្រោយ:ត/ហត)




រូបភាព៩ : កសិកម្មពនេចរ និងខ្ទមចំការ ជាប់នឹងផ្លូវគ្រួសក្រហម ដែលអនាគតអាចក្លាយជាលំនៅដ្ឋានអចិន្ត្រៃយ៍

**តារាងក្រឡាផ្ទៃតាមផលិតភាពដី ការប្រើប្រាស់ និងផលិតផល**

| ល.រ | ចំណាត់ថ្នាក់ដីមានជីជាតិ (តាមបច្ចេកទេស) | ចំណាត់ថ្នាក់ដីមានជីជាតិ (តាមមូលដ្ឋាន) | ផ្ទៃក្រឡា ហិចតា |
|---|---|---|---|
| ១ | **ដីមានផលិតភាពទាប** | ល្បាយខ្សាច់ - ល្បាយគ្រួស | |
| | ចំការបោះបង់ដុះស្មៅ | ស្មៅ ស្បូវ បន្ទាអូរយ៉ាក់ ល្វៀង... | ១១.៦៧ |
| | ចំការបោះបង់ដុះព្រៃគម្ពោធ | មានព្រៃគុម្ពោធ:ដើមកូនសុក្រំ កូនកកោះ កូនស្រឡៅ កូនចំបក់.... | ៩៨.៨៨ |
| | កន្លែងកប់ខ្មោច | ព្រៃរបោះឬព្រៃស្រោងសើមមានដើមឈើច្រើន | ២.៧០ |

| | | | |
|---|---|---|---|
| | ព្រៃរបោះ | មានដើមត្រាច ខ្លង ពពេល ធ្នឹក... | ១២៣.៨០ |
| | ព្រៃស្រោងសើម | បេង នាងនួន កកោះ ស្រឡៅ ក្រញូង ឈើទាល សុក្រំ គគីរ សាខាវ ។ល។ | ១០៧៩.១០ |
| | វាលស្មៅ | ស្មៅចិញ្ចៀន ស្មៅកន្ត្រើយ និងប្រភេទស្មៅផ្សេងៗ ទៀតជាច្រើន | ២.៨១ |
| | បឹង | ត្រី និងធនធានជីវៈច្រើនប្រភេទ ប្រភពផ្ដល់ទឹកសំរាប់ស្រោចស្រព្វដំណាំស្រែ ចំការ | ៨.0៤ |
| | ព្រៃចំរុះ( ស្រោង និង របោះ) | រួមមានឈើត្រាច ធ្នឹក ខ្លុង ពពេល បេង នាងនួន កកោះ ស្រឡៅ ក្រញូង ទាល សុក្រំ គគីរ ។ល។ | ១៣១៤.១៧ |
| | ព្រៃដុះឡើងវិញ | មានដើមសុក្រំ កកោះ ស្រឡៅ ចំបក់ ពពេល ផ្ទៀក ផ្គុក... | ១៩៨៦.១៤ |
| | ព្រៃគម្ពោច | ចុល្លព្រឹកក្រាស់ វាលស្មៅ និងដើមឈើមួយចំនួនទៀត ដែលអាចក្លាយទៅជាឈើធំៗប្រសិនបើយើងមិនកាប់វា | ១៤៥២១ |
| | ព្រៃគម្ពោចលាយដើមឈើធំមួយៗ | មានឈើត្រាច ធ្នឹក ខ្លុង ពពេល នាងនួន កកោះ ស្រឡៅ ក្រញូង សុក្រំ គគីរ ។ល។ | ១១៤.៤៦ |
| | ដីកសិកម្មពនេចរ | ភាគច្រើនដាំចេក,អំពៅ,ដំឡូង, ពោត,សណ្ដែក,ស្ពៃ. សាឡាត់.... | ៣៩៨.១២ |
| | ដីលំនៅដ្ឋាន ភូមិ | ចេក ដូង ដំឡូង ស្វាយ ល្ហុត ខ្នុរ ម្ទេស ស្ពៃ ននោង ត្រឡាច ល្ពៅ ស្លឹកគ្រៃ... | ៦៨.៦៧ |
| | ស្រូវវស្សា | ស្រូវធ្ងន់ :នាងនួ,ក្រមួនស សូមាលី<br>ស្រូវស្រាល : នាងខួន ក្រចកចាប ប្រវិកស ស្រូវ ៥00គ្រាប់<br>ស្រូវកណ្ដាល : ស្រូវដំណើប ចំបើងឈឿង ប្រកិន ផ្កាខ្ញី | ៧១២.៤0 |
| **២** | **ដីមានផលិតភាពខ្ពស់** | ល្បាយឥដ្ឋ-កណ្ដេងប្រផេះល្បាប់អាចម៏កណ្ដុរ | |
| | ចំការបោះបង់ដុះស្មៅ | ស្មៅ ស្បូវ បន្ទាអូរយ៉ាក់ ល្វៀង... | ១0.៨៧ |
| | កន្លែងកប់ខ្មោច | ព្រៃរបោះឬព្រៃស្រោងសើមមានដើមឈើច្រើន | ៤.៣៤ |
| | ព្រៃរបោះ | រួមមានត្រាច ធ្នឹក ខ្លុង ពពេល ។ល។ | ៦៦៥.៩៨ |
| | ព្រៃស្រោងសើម) | បេង នាងនួន កកោះ ស្រឡៅ ក្រញូង ឈើទាល សុក្រំ គគីរ សាខាវ ។ល។ | ១0៧៩.១0 |
| | វាលស្មៅ | ស្មៅចិញ្ចៀន ស្មៅកន្ត្រើយ និងប្រភេទស្មៅផ្សេងៗ ទៀតជាច្រើន | ៩.៣៤៥ |
| | បឹង | ត្រី និងធនធានជីវៈច្រើនប្រភេទ ប្រភពផ្ដល់ទឹកសំរាប់ស្រោចស្រព្វដំណាំស្រែ ចំការ | ២.៣៥ |
| | វាលភក់ | ដីល្បាប់ពុំមានស្មៅឬកូនឈើដុះនោះទេ | ៥.៤៣ |

| | | | |
|---|---|---|---|
| | ព្រៃចំរុះ( ស្រោង និង របោះ) | រួមមានឈើត្រាច ផ្ចឹក ខ្លុង ពពេល បេង នាងនួន កកោះ ស្រឡៅ ក្រញូង ទាល សុក្រំ គគីរ ។ល។ | ១៤២០.២៦ |
| | ទន្លេ ស្ទឹង អូរ | ជាប្រភពយកខ្សាច់ យកធនធានមច្ឆា ជាប្រព័ន្ធស្រោចស្រព្វដល់ដីស្រែ ដីចំការ និងការពារជីវៈចំរុះ | ០.១៨ |
| | ព្រៃដុះឡើងវិញ | មានដើមសុក្រំ កកោះ ស្រឡៅ ចំបក់ ពពេល ផ្ទៀក ផ្លុក... | ១៩៥២.២៧ |
| | ព្រៃគម្ពោច | ចុល្លព្រឹកក្រាស់ វាលស្មៅ និងដើមឈើមួយចំនួនទៀតដែលអាចក្លាយទៅជាឈើធំៗប្រសិនបើយើងមិនកាប់វា | ១១០.៧៧ |
| | ព្រៃគម្ពោចលាយដើមឈើធំមួយៗ | មានឈើត្រាច ផ្ចឹក ខ្លុង ពពេល នាងនួន កកោះ ស្រឡៅ ក្រញូង សុក្រំ គគីរ ។ល។ | ៧៤.៨៧ |
| | ដីកសិកម្មពនេចរ | ភាគច្រើនដាំចេក,អំពៅ,ដំឡូង, ពោត,សណ្តែក,ស្ពៃ. សាឡាត់.... | ៣៨២.៣៧ |
| | ដីលំនៅដ្ឋានភូមិ | ចេក ដូង ដំឡូង ស្វាយ ល្មុត ខ្នុរ ម្ទេស ស្ពៃ ននោង ត្រឡាច ល្ពៅ ស្លឹកគ្រៃ... | ៦៨.៦៦ |
| | ស្រូវវស្សា | - សំរាប់ស្រូវធ្ងន់ :នាងនូ,ក្រមួនស សូមាលី<br>- ស្រូវស្រាល : នាងខួន ក្រចកចាប ប្រវិកស<br>- ស្រូវកណ្តាល : ស្រូវដំណើប ចំបើងលឿង ប្រកិន ផ្កាខ្ញី | ៨៤៨.៤៨ |
| | | **សរុបទាំងអស់** | **៦៩៦១** |

ប្រភព: ទិន្នន័យ GIS ថ្នាក់ជាតិ/សមាសភាគរៀបចំដែនដី/អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម




**រូបភាព១០:**ផែនទីផលិតភាពដី

## ១.៣.៤ ធនធានធម្មជាតិ

### ១.៣.៤.១ ធនធានព្រៃឈើ

ឃុំប៉ុងសំបូរទៅដោយធនធានធម្មជាតិជាច្រើនដូចជាព្រៃឈើសំខាន់ៗ ដែលមានមុខងារផ្នែក អេកូឡូស៊ី នឹង មុខងារផ្នែកសេដ្ឋកិច្ចយ៉ាងសំខាន់ដែលមានឈើសំណង់ ដូចជាឈើ គគី ស្រឡៅ កកោះ សុក្រម ឈើទាល ផ្ចឹក នាងនួន បេង ធ្នង់ ក្រញូង ដែលប្រភេទឈើទាំងនោះដុះនៅតាមព្រៃស្រោង និងនៅតាមភ្នំ ។ ចំណែកសត្វព្រៃ ដូចជា ឈ្លូស ប្រើស ជ្រូកព្រៃ ខ្ទីង សំបូរនៅតាមព្រៃស្រោង ។ បច្ចុប្បន្ននេះធនធានដែលមានតំលៃទាំងនេះត្រូវបានបាត់បង់ បន្តិចម្តងៗ ដោយសារការបំផ្លាញពីក្រុមមនុស្សមួយចំនួនរបស់ក្រុមហ៊ុនខ្សាចគ្រោះ ព្រៃសម្បទាន ព្រមទាំងការ ប្រើប្រាស់មិនសមស្របរបស់ប្រជាពលរដ្ឋ ។ បច្ចុប្បន្នប្រជាជននៅក្នុងឃុំ បានកំពុងយកចិត្តទុកដាក់លើការ ការពារ ធនធានព្រៃឈើ ក៏ដូចជាធនធានធម្មជាតិ សត្វព្រៃ ជីវៈចំរុះឡើងវិញដោយមានបង្កើតគំរោងសហគមន៍ព្រៃឈើ ។ល។

### ១.៣.៤.២ ធនធានជលផល

ឃុំប៉ុងជាឃុំនៅជាប់ដងទន្លេសេសាន ដែលកាលពីមុខទន្លេសេសាននេះសំបូទៅដោយ មច្ឆាជាតិ និងជីវះចំរុះ គ្រប់ប្រភេទ និងនៅបាតទន្លេ មានខ្សាច់ មាស ដែលជាចំណូល សំរាប់សេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋមួយភាគធំដែ រ

តែមកដល់បច្ចុប្បន្ននេះ បើពិនិត្យលើស្ថានភាពនៅក្នុងឃុំប៉ុងសព្វថ្ងៃនៅតាមដងទន្លេសេសាន ធនធានជលផល មានការថយចុះ ដូចជាត្រី និងជីវៈចំរុះដែលផលប៉ះពាល់នោះបានបណ្តាលមកពីនៅប្រទេសវៀតណាមគេមានការសាងសង់ទំនប់វារីអគ្គិសនី បានធ្វើអោយទឹកទន្លេមានការឡើងចុះខុសរដូវ ដែលបណ្តាលអោយប៉ះពាល់ដល់ដំណាំ កសិកម្ម និងបន្លែដែលដុះនៅតាមច្រាំងមាត់ទន្លេ របស់ប្រជាពលរដ្ឋមួយភាគធំ ។

បច្ចុប្បន្នប្រពលរដ្ឋនៅក្នុង ឃុំប៉ុងមានតែពឹងពាក់ទៅលើប្រភពអូរតូចៗ នៅក្នុងឃុំបណ្តោះដែលប្រជាជនអាចរកត្រី ក្តាម ខ្ចង នៅតាមដងអូរ ដោយសារការថយចុះមច្ឆជាតិ នៅក្នុងទន្លេដែលបណ្តាលមកពីផលប៉ះពាល់វារីអគ្គិសនីនៅប្រទេសវៀតណាម។

## ១.៤ ទីផ្សារ និងខ្សែសង្វាក់ផលិតផល

### ១.៤.១ ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ

ស្ថានភាព

- តម្លៃស្រូវ ១ គីឡូក្រាម = ៨00រៀល
- អង្ករ ១គីឡូក្រាម = ២.៥00 រៀល
- សាច់ជ្រូក ១គីឡូក្រាម = ១២.000រៀល
- សាច់ត្រី ១គីឡូក្រាម = ១៣.000រៀល
- មាន់ ១ តំលៃ ២0.000 រៀល
- សាច់គោ ១គីឡូក្រាម = ១៨.000 រៀល
- គ្រឿងផ្ទះ ១ គូប = ៥00.000 រៀល
- ខ្សាច់ ១គូប = ១0.000 រៀល
- គ្រួស ១ គូប= ៣0.000រៀល

### ១.៤.២ ខ្សែសង្វាក់ និងចរាចរផលិតផល

- ការទិញចូលស្រូវអង្ករ បានទិញពីអ្នកភូមិ ជិតខាង និងភូមិខ្លួនឯង តែក៏មានមួយចំនួនតូចទិញពីផ្សារដែលអង្ករនៅលើទីផ្សារត្រូវបាននាំចូលពីទីរួមខេត្ត ស្ថិតនៅក្រុងបានលុង ។
- ការលក់ចេញនូវ ផលអនុផលព្រៃឈើ ប្រជាជនបាននាំយកទៅលក់នៅទីរួមខេត្ត ជួនកាលក៏មានឈ្មួញមកពីក្រៅមកទិញដែរ ភាគច្រើនតម្រូវការរបស់ឈ្មួន រួមមានឈើ និងអនុផលព្រៃឈើខ្លះៗដែរ ។
- ចំពោះផលនេសាទវិញ សព្វថ្ងៃប្រជាជននៅក្នុងឃុំមិនមានការនាំចេញទេព្រោះការ រកផលនេសាទមានការថយចុះដូចច្នេះប្រជាពលរដ្ឋរកបានត្រឹមតែបង្គ្រប់នៅក្នុងជីវភាពគ្រួសារតែប៉ណ្ណោះ ។

### ១.៤.៣ ឱកាស និងឧបស័គ្គ

នៅក្នុងឃុំប៉ុងមាន ធនធានព្រៃឈើ ផ្តល់នូវប្រភពជាចំណីអាហារ អុសដុត សំភារៈប្រើប្រាស់ ប្រភពចំណូលសំរាប់ប្រជាជនមូលដ្ឋាន តែធនធានព្រៃឈើកំពុងតែទទួលការគំរាមកកំហែង និងត្រូវបានបាត់បង់ បន្តិចម្តងៗដោយ

សារការបំផ្លាញពីក្រុមមនុស្សមួយចំនួនរបស់ក្រុមហ៊ុនខ្សាចគ្រោះ ព្រៃសម្បទាន ព្រមទាំងការ ប្រើប្រាស់មិនសមស្រប របស់ប្រជាពលរដ្ឋ កត្តាទាំងនេះបានធ្វើអោយឃុំបាត់បង់នូវចំណូលនូលសេដ្ឋកិច្ចយ៉ាងធំ ហើយការបាត់បង់នេះនឹងមានផលប៉ះពាល់ដល់កូនចៅជំនាន់ក្រោយថែមទៀតផង ។

ចំពោះធនធានជលផល គឺជាធនធានមួយដែលមានសក្តានុពលយ៉ាងខ្ពស់ ក្រៅពីការផ្តល់ជាអាហារ គឺជាប្រភពចំណូលមួយយ៉ាងសំខាន់សំរាប់ប្រជាពលរដ្ឋនៅក្នុងឃុំ ក៏ដូចជាសេដ្ឋកិច្ចជាតិ តែបច្ចុប្បន្នការប្រើប្រាស់ធនធានមានការប៉ះពាល់ គឺធ្វើអោយធនធានទទួលរងនូវគ្រោះថ្នាក់យ៉ាងខ្លាំង ដោយសារការរកផលនេសាទមានលក្ខណៈអនាធិបតេយ្យ ដូចជាការបំពុល ការប្រើម៉ងមានក្រឡាតូច ។ ល។ ចំណែកផលប៉ះពាល់ដ៏ធំមួយទៀតគឺមកពីការសាងសង់វារីអគ្គីសនីនៅប្រទេសវៀតណាម ដែលធ្វើអោយទឹកទន្លេមានសកម្មភាពខុសប្រក្រតីជួនកាលស្រកអស់តែម្តង ជួនកាលទឹកអាចឡើង រីឯទឹកមានភាពល្អក់ដែលធ្វើអោយមច្ឆាជាតិ និងជីវៈចំរុះមួយភាគធំមិនអាចរស់នៅបាន និងមួយភាគធំប៉ះពាល់ដល់ដំណាំកសិផល និងបន្លែធម្មជាតិដែលដុះនៅតាម ដងទន្លេថែមទៀតផង ។

# ជំពូក២
# ការវិភាគតម្រូវការសំរាប់អនាគត

## ២.១ តំបន់សេដ្ឋ

នៅក្នុងឃុំប៉ុងមានតំបន់បីកន្លែងដែលប្រជាជននៅទីនោះបានចាត់ទុកជាតំបន់ដែលមានសារៈសំខាន់គឺ :

- តំបន់ការពារដោយសហគមន៍ បឹងបានហ្វាំង ដែលតំបន់នោះមានសក្តានុពលសំបូរទៅដោយ មច្ឆាជាតិ ហើយត្រូវបានទទួលការរងគ្រោះ ដោយការឆក់ និង បំពុលដោយជនខិលខូច ។ បច្ចុប្បន្នសហគមន៍បានយកចិត្តទុកដាក់ការពារបឹងនេះឡើងវិញដើម្បីថែរក្សាធនធាននៅក្នុងបឹងអោយមាននិរន្តរភាពសំរាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជននៅក្នុងតំបន់ ។

- តំបន់ព្រៃសហគមន៍ឃុំប៉ុងមានពីរកន្លែង តំបន់ទី១មានផ្ទៃក្រឡា៦៥ហិកតា និងតំបន់ទី២ មានផ្ទៃក្រឡា ១.០១៦ហិកតាដែលតំបន់ទាំងពីរមានសក្តានុពលធនធានព្រៃឈើប្រណិត១គ្រប់ប្រភេទនិងសត្វព្រៃដ៏សំបូរបែប តំបន់នេះត្រូវបានចាត់ទុកជាតំបន់អភិរក្ស និងការពារព្រៃសហគមន៍សំរាប់ការពារមិនអោយមានការកាប់រាន រឺ ការឈូសឆាយដើម្បីពង្រីកដីលំនៅដ្ឋាន ឬមានការអភិវឌ្ឍន៍ក្នុងទ្រង់ទ្រាយធំបានឡើយ ។

- ចំណុចដែលគួរអោយកត់សំគាល់មួយទៀតគឺឃុំមានការពិបាកតាមដងទន្លេ ដោយសារទឹកមានការស្រកនិងឡើងខុសប្រក្រតីដែលធ្វើអោយប្រជាជនខូចខាតផលដំណាំស្រែ និងចំការស្ទើរតែរាល់ឆ្នាំ។

## ២.២ ការប្រឈម/ឧបសគ្គ

បច្ចុប្បន្នការរស់របស់ប្រជាពលរដ្ឋនៅក្នុងឃុំប៉ុងបានជួបប្រទះនូវបញ្ហាចំបងមួយចំនួន សំរាប់ការអភិវឌ្ឍន៍ក្នុងមូលដ្ឋានរបស់ខ្លួន ដែលក្រុមប្រឹក្សាឃុំក៏ដូចជាប្រជាជនបានលើកយកមកង្ហាញ រួមមានៈបញ្ហាសេដ្ឋកិច្ច និង សង្គមកិច្ច ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិ ។

ឃុំប៉ុងមានផ្ទៃដីធំទូលាយ តែទិន្នផលដំណាំដែលបានមកពីរបរកសិកម្មរបស់ប្រជាពលរដ្ឋទទួលបាននៅទាបនៅឡើយ ដូចជាផលស្រូវទទួលបានជាមធ្យមពី១.៥ ដល់ ២ តោនក្នុងមួយហិចតាសំរាប់ផ្គត់ផ្គង់តែការហូបចុក និង ដំណាំរួមផ្សំ បន្លែ ផ្លែឈើ ពុំអាចផ្គត់ផ្គង់តំរូវការហូបចុកគ្រប់គ្រាន់ ទាមទារមានការនាំចូលពីទីរួមខេត្ត បច្ចុប្បន្ននេះឃុំពុំទាន់បានទាញយកផលប្រយោជន៍ពីសក្តានុពលលើវិស័យទាំងនេះបានសមស្របនៅឡើយ ដោយមានប្រជាពលរដ្ឋចំនួនប្រមាណ៦០-៧០%រកចំណូលបានទាបគឺជាអ្នកដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ ហើយការប្រើប្រាស់ដីស្រែ និងដីចំការកន្លងមកប្រជាជននៅក្នុងឃុំពួកគាត់មិនបានគិតពីផលប៉ះពាល់ទៅលើដីនៅឡើយ ទាំងនេះគឺអាស្រ័យលើការប្រើប្រាស់ដែលពុំបានគិតពីលក្ខណៈបច្ចេកទេសកសិកម្មធ្វើអោយដីទទួលរងនូវគ្រោះថ្នាក់នៃការបាត់បង់ជីជាតិ ដែលមូលហេតុនេះរួមមានជាអាទិ៍ មកពីការធ្វើកសិកម្មមិនមានបច្ចេកទេសគ្រប់គ្រាន់ ការដាំដំណាំដដែល១លើផ្ទៃដីតែមួយ ការប្រើប្រាស់ជីគីមីមិនត្រឹមត្រូវដែលធ្វើឱ្យដីខ្សោះជីជាតិ និងខូចរចនាសម្ព័ន្ធដី ក៏ដូចជាសារធាតុជីវៈចំរុះក្នុងដី ។

ម៉្យាងវិញទៀតឃុំតែងតែជួបនូវបញ្ហាគ្រោះទឹកជំនន់ និងរាំងស្ងួតដែលធ្វើអោយលិចលង់ និងស្ពកខូចស្រូវស្រែចំការហើយមានការខូចខាតលើហេដ្ឋារចនាសម្ពន័ ដូចជាផ្លូវក្នុងការធ្វើដំណើរហើយមួយទៀតកុមារភាគច្រើនមិនបានចូលរៀន ក្រុមជនងាយរងគ្រោះដូចជាជនពិការ ស្ត្រីមេម៉ាយ កុមារកំព្រា និងមនុស្សចាស់ជរាជាពិសេសបញ្ហាសុខភាព

ក៏ជាអាទិភាពមួយដ៏ចំបងរបស់ឃុំ មូលហេតុដោយសារតែមណ្ឌលសុខភាពនៅឆ្ងាយ ហើយសេវាដឹកជញ្ជូនអ្នកជំងឺនៅពុំទាន់បានដោះស្រាយនៅឡើយ ។ ចំពោះបញ្ហាកើតឡើងដែលគួរអោយកត់សំគាល់នៅតាមដងអូរ និងបឹង គឺមានការឆក់ និងប្រើថ្នាំបំពុល ដែលធ្វើអោយមានការប៉ះពាល់លើបរិស្ថាន និងមច្ឆាជាតិ ជាពិសេស បឹងបានហ៊ុំងដែលជាកន្លែងការពារ សំរាប់សហគមន៍ឃុំប៉ុងដែលបច្ចុប្បន្នឃើញថាមច្ឆាជាតិមានការថយចុះយ៉ាងខ្លាំង។ តាមការវិភាគបញ្ហានៅក្នុងឃុំឃើញថាមានការកើនឡើង អ្នកចំណូលមករស់នៅក្នុងឃុំ ច្រើនគួរអោយកត់សំគាល់ កត្តានេះធ្វើអោយមានការបាត់បង់ព្រៃឈើ ក៏ដូចជាសត្វព្រៃផងដែរ មូលហេតុដោយ សារការកាប់រាន ដើម្បីបានដីមក ធ្វើជាកម្មសិទ្ធិ និងសំរាប់លក់ ។ ការប្រឈមទាំងអស់ខាងលើនេះ នឹងនាំមកនូវ តម្រូវការដីកាន់តែច្រើន ដែលក្នុងនោះ មានទាំងដីសំរាប់ បង្កបង្កើនផលនិងដីសំរាប់តែកម្មសិទ្ធិ ហើយជាលទ្ធផលរួមគឺការបាត់បង់ ព្រៃលិចទឹក វាលស្មៅ និងបឹងបួរធម្មជាតិហើយនាំទៅដល់ការបាត់បង់ធនធានព្រៃលិចទឹក ធនធានជលផល ជីវៈចំរុះ ហើយបច្ច័យ ចុងក្រោយគឺធនធានដី កាន់តែរេចរិលជាបន្តបន្ទាប់។

## ២.៣ តម្រូវការនៃការអភិវឌ្ឍន៍ និងគោលដៅយុទ្ធសាស្ត្រឃុំប៉ុង

ដើម្បីទ្រទ្រង់បាននូវយុទ្ធសាស្ត្ររួមសំដៅធ្វើអោយការអនុវត្តន៍ សំរេចបានដល់គោលដៅនៃចក្ខុវិស័យដែលបានកសាងខាងលើចាំបាច់ត្រូវកសាងយុទ្ធសាស្ត្រតាមវិស័យសំខាន់៧ដែលពាក់ពន្ធ័មួយចំនួនដល់ការអភិវឌ្ឍន៍ឃុំប៉ុង។ យុទ្ធសាស្ត្រតាមវិស័យសំខាន់៧ទាំងនោះក្រុមប្រឹក្សាឃុំនិងគផថនិងប្រជាពលរដ្ឋទាំងអស់នៅក្នុងឃុំ បានជ្រើសរើសយកគោលដៅចំនួន ១០ គឺៈ

១- ប្រជាពលរដ្ឋប្រុសស្រី ក្មេង ចាស់ ឆ្នាំ ២០០៨ - ២០២២ ទទួលបានទិន្នផលស្រូវខ្ពស់ និងទិន្នផលឈើហូបផ្លែ និងលក់បានជាប្រចាំ មានរបព័ន្ធស្រោចរសព្វដំណាំស្រូវ និងដំណាំកសិកម្មគ្រប់មុខបានគ្រប់គ្រាន់មានជីវភាពធូធារបានល្អប្រសើរ ។

២- ប្រជាពលរដ្ឋរស់នៅក្នុងឃុំ និងមានកំលាំងអូសទាញសុខភាពសត្វទ្រទ្រង់បានល្អ បង្កបង្កើនផលងាយស្រួលបានល្អប្រសើរ ។

៣-ប្រជាពលរដ្ឋប្រុសស្រី ក្មេង ចាស់ មានផ្លូវធ្វើដំណើរងាយស្រួលក្នុងការទំនាក់ទំនង និងប្រកប របរប្រចាំថ្ងៃមានជីវភាពធូធារបានល្អប្រសើរ ។

៤- ប្រជាពលរដ្ឋប្រុសស្រី ក្មេង ចាស់ឆ្នាំ ២០០៨ ដល់ ឆ្នាំ ២០២២ បានទទួលសេវាសុខភាព សហគមន៍មានសុខភាពល្អប្រសើរ

៥- កុមារា កុមារីទៅថ្ងៃមុខមានចំណេះដឹង និងមានធនធានមនុស្សភាគច្រើនបានល្អប្រសើរ

៦- ប្រជាពលរដ្ឋប្រុសស្រីទូទាំងឃុំទៅមុខ ទទួលបានផល អនុផលព្រៃឈើសត្វព្រៃនាំលក់ និងយកមកហូបចុកជាប្រចាំ។

៧- ប្រជាពលរដ្ឋប្រុសស្រីទូទាំងឃុំមានត្រីហូប និងបានលក់ជាប្រចាំ មានជីវភាពរស់នៅធូធារ និងធនធានធម្មជាតិ មច្ឆាជាតិ បរិស្ថាន គង់វង្សបានល្អប្រសើរ ។

៨- ប្រជាពលរដ្ឋមានប្លង់ដីនិងមានកម្មសិទ្ធដី បានគ្រប់គ្រាន់បានល្អប្រសើរកាត់បន្ថយទំនាស់ដីធ្លីជាអតិបរិមារ

៩-ប្រជាពលរដ្ឋប្រុសស្រីទូទាំងឃុំមានសណ្តាប់ធ្នាប់សង្គមបានល្អប្រសើរ ប្រជាពលរដ្ឋនៅក្នុងឃុំមានសាមគ្គីគ្នា
១០- ប្រជាពលរដ្ឋទូទាំងឃុំគ្មានអំពើហឹង្សាក្នុងគ្រួសារ និងពុំមានការរំលោភបំពានលើស្ត្រីភេទ ។

## ២.៤ តម្រូវការជីសំរាប់អនាគត

### ២.៤.១ ប្រជាសាស្ត្រ

#### ២.៤.១.១ អត្រាកំណើន

ស្ថានភាពអត្រាកំណើននៃ ប្រជាពលរដ្ឋនៅក្នុងឃុំប៉ុង បើពិនិត្យនៅក្នុងឆ្នាំ ២០០៥ មានចំនួនគ្រួសារ ៣៩៣ គ្រួសារ ដែលស្មើនឹងប្រជាពលរដ្ឋ ចំនួន ២១៤៣នាក់ បើយើងធ្វើការប្រៀបធៀបនៅឆ្នាំ ២០០៦ មានការកើនឡើងតែ ៦ គ្រួសារស្មើ ៨៧នាក់ ដូចនេះចំពោះចំនួនមនុស្សមានចំនួនច្រើនជាងនៃចំនួនគ្រួសារ ។ តែចំនួនគ្រួសារក្នុងឆ្នាំ ២០០៦ នេះមានចំនួន ៣៣៩គ្រួសារ ស្មើនិង ២២៣០នាក់ ។ តែបើយើង ពិនិត្យទៅលើឆ្នាំ ២០០៦ ធៀបទៅនឹងឆ្នាំ ២០០៧ ឃើញថាមានការកើនឡើងនៃចំនួនគ្រួសាររហូតដល់ ៦១គ្រួសារស្មើនឹងចំនួនគ្រួសារ ២៣៤ នាក់ ដែលចំនួន គ្រួសារឆ្នាំ ២០០៧ នេះមានចំនួន ៤៦០ គ្រួសារ ស្មើនិង ២៤៦៤ នាក់ ចំណែកឯ ឆ្នាំ ២០០៨ មានការថយចុះចំនួន គ្រួសារច្រើនជាងឆ្នាំ ២០០៦-២០០៧ បើធៀបជាមួយឆ្នាំ ២០០៧-២០០៨ មានការកើនឡើងតែ ៦គ្រួសារស្មើនិង ៦២ នាក់តែប៉ុណ្ណោះ តាមការសាកសួរព័តិមានពីក្រុមប្រឹក្សាឃុំ និង អ្នកចូលរួមនៅក្នុងឃុំ ដែលបណ្តាលមកពីការ ឡើងចុះនៃចំនួនប្រជាពលរដ្ឋនៅក្នុងឃុំ គឺបណ្តាលមកពីការហូរចូល និងធ្វើចំណាកស្រុកចេញទៅរកមុខរបរនៅក្រៅមូលដ្ឋាន តែចំនួនគ្រួសារ និងចំនួនប្រជាពលរដ្ឋតាមបណ្តាឆ្នាំមានការ កើនឡើងជាលំដាប់ ហើយចំនួនកុមារ ក៏មានការ កើនឡើងដែរ កត្តានេះហើយដែលបណ្តាលអោយមានការកង្វះខាតនៅទីកន្លែងសិក្សា និងមានការខ្វះខាតដីក្នុងការ ពង្រីកដីនៅក្នុងវិស័យកសិកម្មដែរ ដូច្នេះយើងក៏ត្រូវកំណត់នូវសក្តានុពលមួយចំនួនដូចជាលទ្ធភាពនៃកាពង្រីកអាគារ សិក្សា ការង្កើនមុខរបរការធ្វើស្រែបង្កើនរដូវ ការបង្កើននូវទិន្នផលកសិកម្មការរៀបចំប្រព័ន្ធស្រោចស្រព្វការអភិរក្ស នូវធនធានធម្មជាតិ និងការកំណត់នៃការប្រើប្រាស់ធនធានអោយបានសមស្របទើបអាចធានាបាននូវអត្រាកំណើន ។

<u>តារាង ការគណនាអត្រាកំណើនមធ្យម</u>

| **ចំនួនគ្រួសារ/ប្រជាជន** | **២០០៥** | **២០០៦** | **២០០៧** | **២០០៨** | **កំណើនមធ្យម** | **កំណើន/ឆ្នាំ** |
|---|---|---|---|---|---|---|
| ចំនួនគ្រួសារសរុប | ៣៩៣ | ៣៩៩ | ៤៦០ | ៤៦៧ | - | - |
| អត្រាកំណើនគ្រួសារ | - | ២% | ១៥% | ២% | ៦% | ២៨គ្រួសារ |
| ចំនួនប្រជាជនសរុប | ២១៤៣ | ២២៣០ | ២៤៦៤ | ២៥២៦ | - | - |
| អត្រាកំណើនប្រជាជន | - | ៤% | ១០% | ៣% | ៦% | ១៩២នាក់ |

**<u>ប្រភព:</u>** ឯកសារ ស្តីពីស្ថានភាពឃុំ ឆ្នាំ ២០០៩

នៅក្នុងអត្រានៃការប្រែប្រួលចំនួនគ្រួសាររបស់ប្រជាពលរដ្ឋ នៅក្នុងអំឡុងឆ្នាំ ២០០៥-២០០៦ ឃើញថាមានការកើនឡើង តែ ២% ប៉ុន្តែឆ្នាំ ២០០៦-២០០៧ អត្រាកើនឡើងមានការប្រែប្រួលរហូតទៅដល់ ១៥ % ប៉ុន្តែ ២០០៧-២០០៨ អត្រាប្រជាជនមានការថយចុះទៅវិលគឺមានការកើនឡើងតែ ២%ប៉ុណ្ណោះ នេះបញ្ជាក់អោយឃើញថាប្រជាជនឆ្នាំ ឆ្នាំ ២០០៦-២០០៧ មានការហូរចូលច្រើន ។ ក្នុងនោះដែរបើតាមការគណនាអត្រាកំណើនចំនួនគ្រួសារពីឆ្នាំ ២០០៥-២០០៨ ឃើញថាអត្រាកំណើនមាន ៦% ស្មើនិង ២៨គ្រួសារក្នុងមួយឆ្នាំ ។

ផ្អែកតាមទិន្នន័យព័តិមាននៃផែនការអភិវឌ្ឍន៍ឃុំ និងតាមរយះការគណនា រកអត្រាកំណើនរបស់ប្រជាពលរដ្ឋឃើញថា ចំនួនប្រជាជនពីមួយឆ្នាំ ទៅមួយឆ្នាំមានការប្រែប្រួលកើនឡើង និងឆ្នាំខ្លះមានការថយចុះ កត្តានេះគឺអាស្រ័យដោយ មូលហេតុដូចករណីខាងលើ ប៉ុន្តែទោះជាយ៉ាងនោះក៏ដោយក៏អត្រាកំណើនជាមធ្យម ៦% ដែលក្នុងនោះមានការកើនឡើងក្នុង ១ ឆ្នាំ ១៥២ នាក់ ។

### ២.៤.១.២ ការធ្វើចំណោលប្រជាសាស្ត្រ

ការធ្វើចំណោលប្រជាសាស្ត្រគឺសំរាប់ការទស្សន៏ទាយកំណើនប្រជាជនជាចំណុចដ៏សំខាន់ណាស់ សំរាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ឃុំប៉ុង ។ ការដឹងជាមុននូវចំនួនដង់ស៊ីតេប្រជាជន គឺជាមធ្យោបាយដ៏សំខាន់មួយដើម្បីធ្វើការកំណត់ជាមុននូវគោលដៅអភិវឌ្ឍន៍សំខាន់ៗរបស់ឃុំ នាពេលអនាគត ។ ដូចនេះការលើកយកចំនួនប្រជាជនក្នុងឆ្នាំ២០០៨ មកធ្វើការប្រៀបធៀប និង ទស្សន៏ទាយពីកំណើនប្រជាជនទៅថ្ងៃអនាគត ( ឆ្នាំ២០០៨ និង ២០២២) គឺជាយុទ្ធសាស្ត្រមួយសំរាប់ប្រើប្រាស់ និង អនុវត្តផែនការអភិវឌ្ឍន៍ឃុំ ក្នុងរយៈពេល ១៥ ឆ្នាំ ។

**តារាងការធ្វើចំណោលប្រជាសាស្ត្រ**

| ស្ថិតិតាមក្រុមអាយុ | ឆ្នាំ ២០១២ | | ឆ្នាំ ២០១៧ | | ឆ្នាំ ២០២២ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | |
| អាយុក្រោម០៥ឆ្នាំ | ៤០៣ | ២០៣ | ៥០១ | ២៥៣ | ៥៩៩ | ៣០២ | |
| អាយុ ០៥ឆ្នាំ | ១៥៨ | ៧៨ | ១៩៦ | ៩៧ | ២៣៤ | ១១៦ | |
| អាយុពី ៦-១១ឆ្នាំ | ៥៣៨ | ២៨៩ | ៦៦៩ | ៣៥៩ | ៨០០ | ៤២៩ | |
| អាយុពី ១២-១៤ឆ្នាំ | ៣០០ | ១៧៩ | ៣៧៣ | ២២២ | ៤៤៦ | ២៦៥ | |
| អាយុពី ១៥-១៧ឆ្នាំ | ៣០៤ | ១៦១ | ៣៧៨ | ២០០ | ៤៥១ | ២៤០ | |
| អាយុពី ១៨-២៤ឆ្នាំ | ៣៧០ | ១៩៦ | ៤៥៩ | ២៤៤ | ៥៤៩ | ២៩១ | |
| អាយុពី ២៥-៦០ឆ្នាំ | ៩៤២ | ៥១៦ | ១១៧០ | ៦៤១ | ១៣៩៨ | ៧៦៦ | |
| អាយុពី៦១ឆ្នាំឡើងទៅ | ១១៩ | ៧៧ | ១៤៨ | ៩៦ | ១៧៧ | ១១៤ | |
| ចំនួនប្រជាជនសរុប | ៣១៣៤ | ១៧០០ | ៣៨៩៤ | ២១១២ | ៤៦៥៤ | ២៥២៤ | |
| ចំនួនគ្រួសារសរុប | ៥៧៩ | | ៧២០ | | ៨៦០ | | |

អត្រាកំណើនប្រជាពលរដ្ឋនៅក្នុងឃុំប៉ុង បើពិនិត្យទៅលើកំណើនក្នុងរយៈពេល ៥ ឆ្នាំសំរាប់រយះពេល ១៥ ឆ្នាំខាងមុខ ឃើញថាអត្រាកំណើនប្រជាពលរដ្ឋជាមធ្យម ៦%ក្នុងនោះស្មើរនិង ១៥២នាក់ ក្នុងមួយឆ្នាំហើយ

និង ៦% ស្មើនិង ២៨គ្រួសារក្នុង ១ឆ្នាំនោះបើពិនិត្យទៅលើបរិមាណផ្ទៃដី ដែលអាចប្រើប្រាស់បាននៅមានក៏រិត ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏យើងត្រូវចាប់អារម្មណ៏ដល់ការអភិវឌ្ឍន៏ដែរ ព្រោះអត្រាកំណើនរបស់ប្រជាពលរដ្ឋនៅក្នុងឃុំប៉ុង គឺវាពាក់ព័ន្ធទៅលើការអភិវឌ្ឍធនធានដែលមានក្នុងឃុំ ពិសេសបរិមាណដី ដែលអាចបង្កើននូវផល ដើម្បីធានាស្បៀងក្នុងតំបន់ ។

### ២.៤.២ តម្រូវការដីសំរាប់លំនៅដ្ឋាន

ចំពោះដីលំនៅដ្ឋានគឺសំដៅទៅដល់ ដីដែលប្រើប្រាស់សំរាប់សង់ផ្ទះ និងសំរាប់ដាំដំណាំសួនគ្រួសារ នៅជុំវិញ (លំអិតសូមមើលឧបសម្ព័ន្ធ១) សំរាប់ឆ្នាំគោល ២០០៨ មានទំហំ ៦៩ហិកតាសំរាប់ប្រជាជនប្រមាណជា ៣៦៦គ្រួសារ ដូច្នេះទំហំដីសំរាប់មួយគ្រួសារគិតជាមធ្យមគឺមានដី០.១៩ហិចតាគឺច្រើនជាងដីសំរាប់សង់លំនៅដ្ឋានដែលមាន ១២០០-៣៦០០ម២ (មាត្រាទី១៥ ជំពូក៤នៃអនុក្រិត្យ ស្តីពីសម្បទានដីសង្គមកិច្ច) ។ អាស្រ័យ ដោយដីនៅក្នុងឃុំប៉ុងមានវិសាលភាពគ្រប់គ្រាន់ ដូច្នេះក្នុងការប៉ាន់ប្រមាណដីសំរាប់សង់លំនៅដ្ឋានត្រូវកំណត់យក ១២០០ម ។ ដើម្បីធានាអោយប្រជាជនដែលខ្វះដី និងប្រជាជនដែលកើនឡើងនៅឆ្នាំ ២០២២ មានដីលំនៅដ្ឋានសមរម្យយើងត្រូវពិចារណាដូចខាងក្រោម:

តម្រូវការដីសំរាប់ឆ្នាំ ២០២២ គឺមាន :

| | |
|---|---|
| - ចំនួនគ្រួសារដែលបច្ចុប្បន្នមិនទាន់មានដីលំនៅដ្ឋាន | ១០១គ្រួ x0.១២ =១២.១២ ហ.ត |
| - កំណើនគ្រួសារ ពីឆ្នាំ ២០០៨-២០២២ | ៣៩៣គ្រួ. x 0,១២ = ៤៧.១៦ ហត. |
| | សរុប ៥៩.២៨ហត. |

### ២.៤.៣ តម្រូវការដីកសិកម្ម

តម្រូវការដីកសិកម្មគឺរួមមានដីសំរាប់ ស្រែវស្សា និង ចំការដំណាំផ្លាស់វេន(លំអិតសូមមើលឧបសម្ព័ន្ធ១) សំរាប់ឆ្នាំគោល២០០៨ មានទំហំ ៨៤៨.៤៨ ហិកតា សំរាប់ ៤១១ គ្រួសារ ដូច្នេះទំហំដីជាមធ្យមសំរាប់មួយគ្រួសារមាន ២.០៦ ហិកតា ។ ដូចនេះប្រជាជនដែលអាចមានដីជាមធ្យមទំហំ ២ ហិកតា ជាទំហំដីមួយសមស្របសំរាប់ ការរស់នៅប្រជាជនមួយគ្រួសារ ។

តម្រូវការសំរាប់ឆ្នាំ ២០២២ គឺមាន :

| | |
|---|---|
| - ចំនួនគ្រួសារដែលបច្ចុប្បន្នមិនទាន់មានដីកសិកម្ម | ៩៨ គ្រួ. x ២ = ១៩៦ ហត. |
| - ចំពោះគ្រួសារមានដីតិចជាង១ហិកតា | ៣២គ្រួ. x (២,0-0,៥0) = ៤៨ ហ.ត |
| - កំណើនគ្រួសារ ២០២២ | ៣៤៦ គ្រួ. x ២ = ៦៩២ហត. |
| | សរុប ៩៣៦ ហត. |

តាមការគណនាខាងលើ ឃើញថាទំហំដីដែលត្រូវការសំរាប់ឆ្នាំ២០២២ មានចំនួន ៦៩២ហ.តគឺសំរាប់តែចំនួនគ្រួសារដែលកើនតែប៉ុណ្ណោះ ។ ចំណែកគ្រួសារដែលបច្ចុប្បន្នមិនទាន់មានដី និងមានដីតិចជាង១ហ.ត គឺរាប់បញ្ចូលក្នុងដី

ដែល មានស្រាប់ ៨៤៨.៤៨ហ.ត។ ក្រុមប្រឹក្សាឃុំធ្វើយ៉ាងណាគ្រប់គ្រងនូវដីដែលមានដើម្បីអោយការប្រើប្រាស់សមស្របជាមួយបរិមាណគ្រួសាររបស់ខ្លួននៅក្នុងឃុំ។

### ២.៤.៤ តម្រូវការដីសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ

ឃុំប៉ុងជាឃុំ សំបូរដោយព្រៃឈើធនធានធម្មជាតិ មានបឹង អូរ និងដីមានជីវជាតិដូចនេះដីដែលបានកំណត់នៅក្នុងតំបន់រសើប គឺមានដីដែលស្នើសុំបង្កើតសហគមន៍ព្រៃឈើ តំបន់ការពារបឹងបានហ្វាំង តំបន់ព្រៃអារក្ស តំបន់គ្រប់គ្រងដោយសហគមន៍ ដែលជាព្រៃស្រោងសើម ព្រៃស្រោងសើម លាយ និងព្រៃរបោះសំរាប់តំបន់អភិរក្ស សត្វព្រៃ និងតំបន់ព្រៃដោះឡើងវិញដែលគ្រប់គ្រងដោយសហគមន៍ ចំណែកដីផ្សេងៗទៀតដែលមិន បានកំណត់ទៅក្នុងប្រភេទនៃការប្រើប្រាស់ដី គឺត្រូវតែទុកអោយនៅជាដីព្រៃ និងវាលស្មៅដីដែលដែលជាដីរបស់រដ្ឋ ដើម្បីធានានូវតម្រូវការដីសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ដែលមានការចាប់អារម្មណ៍ទៅលើការការពារ និងទប់ស្កាត់អោយបានជាដាច់ខាតនូវការលួចកាប់រំលោភយកដី ពីសំណាក់ជនខិលខូច និងចាត់វិធានការអោយបានខ្លាំងខ្លាបំផុតសំរាប់ជនទាំងនោះ ។

### ២.៤.៥ តម្រូវការដីសំរាប់ ហេដ្ឋារចនាសម្ព័ន្ធសង្គម

ជារួមហេដ្ឋារចនាសម័ន្ធសង្គមក្នុងរូបភាពតូចតាច គឺត្រូវបានបញ្ចូលទៅក្នុងដីលំនៅដ្ឋាន ឬដីទីប្រជុំជន ដោយមិនបានញែកចេញដោយឡែកនោះទេ (ក្នុងនោះដីកប់ខ្មោច វត្ត អាស្រម ក៏គិតគូរក្នុងនេះដែរ) តែក្នុងនោះ ក៏មានការគិតគូរជារួម លើកលែងតែហេដ្ឋារចនាសម្ព័ន្ធ សង្គមដែលមានទ្រង់ទ្រាយធំ ទើបមានការគិតគូរដោយឡែក។ និយាយរួមដីសំរាប់តម្រូវការហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានកំណត់ជារួមជាមួយនឹងដីត្រៀមបំរុង សំរាប់ពង្រីកទីប្រជុំជន។

តាមការប៉ាន់ប្រមាណជាសរុប ដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធសង្គមគឺមានតម្រូវការបន្ថែមចំនួន ២ហិកតា ចំពោះផ្លូវ ទំនប់តូចៗ គឺមិនមានការគិតជាផ្ទៃដីទេ តែមានប្រវែងហើយនឹងបង្ហាញក្នុងផែនទីដោយឡែក

(សូម មើលឧបសម្ព័ន្ធ ....ផែនទីហេដ្ឋារចនាសម្ព័ន្ធ...)

<u>តារាងផែនការអភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេវាកម្មទូទៅ</u>

| ហេដ្ឋារចនាសម្ព័ន្ធ | ចំនួនក្នុងឆ្នាំនេះ | ចំនួន១៥ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| សាលាមត្តេយ្យ | ០១ | ០៣ | ០២ |
| សាលាបឋមសិក្សា | ០៣ | ០៥ | ០២ |
| សាលាអនុវិទ្យាល័យ | ០១សាលា (១អាគារ) | ១សាលា(០៣ អាគារ) | ២អាគារបន្ថែម |
| សាលាវិទ្យាល័យ | ០ | ០១ | ០១ |
| មណ្ឌលសុខភាព | ០១ | ០១ | ០ |
| ប៉ុស្តិ៍សុខភាព | ០ | ០១ | ០១ |
| ស្រះទឹក | | ២០ | ២០ |

| | | | |
|---|---|---|---|
| ជីកប្រឡាយ | | ១២ | ១២ |
| សាងសង់ផ្លូវក្រាលគ្រោះក្រហម | | ១៦ | ៤.៥០ |
| សាងសង់លូកាត់ថ្នល់ | | ១៥ | ១៥ |
| សាងសង់បង្គន់អនាម័យ | | ៥០ | ៥០ |
| ជីកអណ្ដូងទឹកស្អាត | | ៤៧ | ៤៧ |
| ស្នាក់ការសហគមន៍នេសាទ | | ២ | ២ |

<u>ប្រភព</u>: ការប្រជុំនៅថ្នាក់ឃុំ

## ២.៤.៥.១ តម្រូវការសាលារៀន

ដីសំរាប់សាងសង់សាលារៀនមានការកំណត់បានច្បាស់លាស់គឺមាន ពីរកន្លែងសំរាប់សាងសង់ អនុវិទ្យាល័យ និងវិទ្យាល័យ ដែលបានកំណត់ដោយឃុំ ហើយដីសាលានេះ វាស្ថិតនៅក្នុងដីលំនៅដ្ឋានភូមិ ដោយឃុំត្រៀមសំរាប់សាងសង់នាពេលខាងមុខ នៅពេលដែលមានចំនួយឧបត្ថម្ភពីសំណាក់រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ។

ចំពោះការអភិវឌ្ឍន៏ និងប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសង្គមនៅក្នុងមូលដ្ឋានឃុំ បច្ចុប្បន្ននៅមានកំរិតហើយ ឃុំមានសាលាអនុវិទ្យាល័យមួយកន្លែង និងមួយអាគារកើតថ្មីក៏ដោយ ប៉ុន្តែទោះបីយ៉ាងនេះក៏ដោយក៏ការអភិវឌ្ឍលើវិស័យអប់រំនៅក្នុងឃុំប៉ុង នៅពុំទាន់បំពេញបាននូវតម្រូវការសិក្សា របស់សិស្សានុសិស្សនៅឡើយ ជាអាទិ៏ដូចជានៅគម្រោងផែនការ ១៥ឆ្នាំខាងមុខតម្រូវការលើ អាគារសិក្សាផ្អែកតាមបរិមាណសិស្សានុសិស្ស គឺ សាលាមតេយ្យ សាលា បឋមសិក្សា ក៏ដូចជាអនុវិទ្យាល័យបើពិនិត្យទៅ តាមការគណនា កំណើនប្រជាពលរដ្ឋឃើញថាតម្រូវការទាំងនេះអាចផ្ដល់ឳកាសអោយឃុំអាចអភិវឌ្ឍន៍ ទៅតាមលទ្ធភាពជាបណ្ដើរៗដែលក្នុងនោះសាលាមត្តេយ្យ ២ សាលានៅភូមិប៉ុង ១ និងភូមិបានហ៊្វាំង ១ ហើយសាលាបឋមសិក្សាឃុំ មានគម្រោងពង្រីក ០១ ទៀតនៅភូមិបានហ៊្វាំង និងវិទ្យាល័យ ឃុំត្រៀមពង្រីក ២ អាគារ ១០បន្ទប់ ដោយឡែកចំពោះសាលាអនុវិទ្យាល័យបច្ចុប្បន្នមាន ១ និង ១ អាគារ ដូច្នេះឃុំមានគម្រោងសាងសង់អាគារបន្ថែម ១អាគារ ៦បន្ទប់ និងវិទ្យាល័យ ១អាគារ ៤ បន្ទប់នៅពេលខាងមុខ។

<u>តារាងកំណើនកុមារ និងតម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០១២-២០២២</u>

| ប្រភេទសាលា | នៅឆ្នាំ ២០១២ | | | នៅឆ្នាំ ២០១៧ | | | នៅឆ្នាំ ២០២២ | | |
|---|---|---|---|---|---|---|---|---|---|
| | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ |
| ថ្នាក់មត្តេយសិក្សា | ១៥៨ | ០ | ២ | ១៥៦ | ០ | ០ | ២៣៤ | ០ | ២ |
| ថ្នាក់បឋមសិក្សា | ៥៣៨ | - | - | ៦៦៩ | ០ | - | ៨០០ | ១ | ៦ |
| ថ្នាក់អនុវិទ្យាល័យ | ៣០០ | ០ | - | ៣៧៣ | ០ | ២ | ៤៤៦ | ១ | ៣ |
| ថ្នាក់វិទ្យាល័យ | ៣០៤ | ១ | ៣ | ៣៧៨ | ០ | ១ | ៤៥១ | ១ | ៤ |

## ២.៤.៥.២ សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត

### ក. សេវាកម្មសុខភាព

បច្ចុប្បន្ននេះឃុំប៉ុង មិនទាន់មានប៉ុស្តិ៍សុខភាពនៅតាមភូមិសំរាប់ជួយសំរួលនូវតម្រូវការ នៃការទ្រទ្រង់សុខមាលភាពរបស់ប្រជាពលរដ្ឋបន្ថែមលើមណ្ឌលសុខភាពឡើយ ចំណែកវេជ្ជបណ្ឌិតនិងគ្រូពេទ្យព្យាបាលជំងឺទូទៅ ក៏ពុំទាន់មានគ្រប់គ្រាន់នៅឡើយដែរ ដែលជាហេតុនាំអោយមានការខ្វះខាតចំពោះសេវាសុខាភិបាល ពីព្រោះប្រសិនបើមានអ្នកជំងឺឈឺធ្ងន់ ត្រូវបញ្ជូនអ្នកជំងឺទាំងនោះទៅមន្ទីរពេទ្យនៅទីរួមខេត្តរតនគិរី ដែលមានចំងាយឆ្ងាយរហូតដល់ ៤១គ.ម ឯណោះ។ ដោយស្ថានភាពភូមិសាស្ត្រនៃឃុំដែលមានប្រជាជនរស់នៅដាច់ឆ្ងាយពីគ្នា និងមានចំងាយផ្លូវឆ្ងាយពីមណ្ឌលសុខភាពឃុំ និងពីឃុំមកខេត្ត បណ្តាលអោយមានការលំបាកក្នុងការធ្វើដំណើរហើយប្រជាពលរដ្ឋ តែងតែជួបប្រទះនូវ ប្រភេទជំងឺច្រើនប្រភេទដូចជានៅរដូវវស្សាប្រជាពលរដ្ឋតែងជួបប្រទះនូវជំងឺគ្រុនចាញ់ គ្រុនឈាម និង នៅរដូវប្រាំងតែងជួបប្រទះជំងឺរលាកផ្លូវដង្ហើមលើ និងផ្លូវដង្ហើមក្រោម ព្រមទាំងជំងឺរាគរូស ។

បច្ចុប្បន្នមណ្ឌលសុខភាពឃុំ កំពុងខ្វះអាគារសំរាប់អ្នកជំងឺសំរាកព្យាបាល ខ្វះគ្រូពេទ្យ និង វេជ្ជបណ្ឌិត សំរាបពិនិត្យ និងព្យាបាលជំងឺ ។ ដោយអ្នកជំងឺមនុស្សចាស់ និង កុមារសំរាកនៅជាមួយគ្នាដែលជាហេតុនាំឱ្យមានបញ្ហាដល់សុវត្ថិភាពចំពោះអ្នកជំងឺ ពីព្រោះកុមារងាយនឹងឆ្លងជំងឺពីមនុស្សចាស់ និងម្យ៉ាងទៀតមានអ្នកជំងឺឈឺធ្ងន់ពុំមានគ្រូពេទ្យ ឬ វេជ្ជបណ្ឌិតពិនិត្យព្យាបាលជំងឺ អោយបានដឹតដល់ ជាពិសេសស្ត្រីមានផ្ទៃពោះប្រហែល៦០%ជាចំនួន ដ៏តិចតួច ដែលបានទទួលសេវាពីពេទ្យឆ្មប ក្រៅពីនោះដែលជាចំនួនច្រើនសុទ្ធតែទទួលសេវាពីឆ្មបបុរាណ។ ដោយឃុំមានប្រជាពលរដ្ឋពុំគ្រប់ចំនួនតាមបទដ្ឋាននៃស្តង់ដាដែលតំរូវឱ្យមានប្រជាពលរដ្ឋគ្រប់ចំនួន ទើបអនុញ្ញាតឱ្យបង្កើតអោយមានប៉ុស្តិ៍សុខ ក៏ដោយក៏គួរបង្កើតឱ្យមានប៉ុស្តិ៍សុខភាពនៅតាមភូមិពីព្រោះឃុំជាតំបន់ដាច់ស្រយាល នៅឆ្ងាយពីទីរួមខេត្ត ដូច្នេះជាអាទិភាព ឃុំត្រូវលើកផែនការសាងសង់ប៉ុស្តិ៍សុខភាព អោយមាននៅតាមភូមិនិមួយៗទើបអាចជួយសំរាលដល់ការលំបាកលើការថែទាំសុខភាពក្នុងមូលដ្ឋាន ។

### ខ. ការផ្គត់ផ្គង់ទឹកស្អាត

ការប្រើប្រាស់ទឹកស្អាតនៅក្នុងឃុំប៉ុង បច្ចុប្បន្ននៅតែជាបញ្ហាចំបងនៅឡើយ ព្រោះថាចំនួនអណ្តូងទឹក ៨១ អណ្តូងដែលបានសាងសង់ពីមុននោះត្រូវបានខូចខាតអស់៨ អណ្តូង ដូច្នេះជាដំណោះស្រាយនៃការអភិវឌ្ឍន៍គឺត្រូវស្តារនិងជួសជុលនូវអណ្តូងទាំង៨នោះឡើងវិញ ។សំរាប់១៥ឆ្នាំទៀតពុំចាំបាច់ពង្រីកបន្ថែមប្រភពទឹកស្អាតទាំងនេះទេ តែឃុំត្រូវគិតគូរបន្ថែមនូវគម្រោងផែនការក្នុងការរៀបចំធ្វើអាងដើម្បីស្តុកទឹកស្អាត ព្រមទាំងផ្តល់ជូនធុងចម្រោះដើម្បីចែកចាយជូនប្រជាពលរដ្ឋប្រើប្រាស់ ។

### ២.៤.៥.៣ ផ្នែកវប្បធម៌ និងសាសនា

នៅក្នុងការអភិវឌ្ឍ ទៅលើផ្នែកវប្បធម៌ជាកត្តា មួយចូលរួមចំណែកជំរុញ អោយមានសន្ទុះដល់ការអប់រំផ្នែកព្រះពុទ្ធសាសនា ។ រាល់ទីតាំងនីមួយៗតាមបណ្តាភូមិ ត្រូវបានផ្តល់លទ្ធភាព និងជួយសំរួល ដល់ប្រជាពលរដ្ឋនៅតាម មូលដ្ឋានផ្ទាល់មានឪកាសចូលរួម ពង្រីកលើការ ផ្សព្វផ្សាយតាមរយៈការអប់រំដល់ យុវជនដែលជាសរសរទ្រូងនៃប្រទេសជាតិអោយជៀសផុតពីអំពើខុសច្បាប់ទាំងឡាយដែលរដ្ឋាភិបាលបានកំណត់។ បច្ចុប្បន្នសំរាប់ឃុំប៉ុងកន្លែងគោរព ប្រពៃណីសាសនា នាថ្ងៃអនាគត ពុំទាន់បានគ្រប់តម្រូវការរបស់ប្រជា ពលរដ្ឋនៅឡើយទេ ។

**<u>តារាងការអភិវឌ្ឍន៍ និងអភិរក្សផ្នែកវប្បធម៌ និងសាសនា</u>**

| វប្បធម៌ និងសាសនា | ចំនួនក្នុងឆ្នាំនេះ | ចំនួន១៥ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| សាលាឆទាន | 0 | ២ | ២ |
| ទីកន្លែងសាការៈបូជា | ១ | ១ | 0 |
| វត្តអារាម | ១ | ១ | 0 |
| ផ្សេងៗ | | | |

### ២.៤.៥.៤ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងប្រព័ន្ធស្រោចស្រព

ផ្អែកតាមស្ថានភាពជាក់ស្តែងនៃបរិមាណផ្លូវដែលមានក្នុងឃុំប៉ុង ឃើញថាផ្លូវក្រាលគ្រួសក្រហមដែលបានសាងសង់ពីមុនមក២ខ្សែមានចំនួន១១.៥0គ.ម បច្ចុប្បន្នត្រូវបានខូច ហើយនៅក្នុងឆ្នាំ២00៩ នេះឃុំបានធ្វើការជួសជុលឡើងវិញបានមួយចំនួន និងមួយចំនួនទៀត នឹងធ្វើការជួសជុលបន្ត ហើយនៅរយៈពេល១៥ឆ្នាំខាងមុខឃុំនឹងលើកគម្រោងសាងសង់ផ្លូវគ្រួសក្រហមបន្ថែម១២ខ្សែទៀតប្រវែង ១៦.៦0គ.ម ជាមួយគ្នានេះដែរឃុំក៏បានលើកគម្រោងផ្លូវក្រាលកៅស៊ូ២ខ្សែមានប្រវែង ២៨.៥0 គ.មដែលកន្លងមកពុំទាន់មាន ។

ដោយឡែកចំពោះផ្លូវ ថ្នើរជើង ឬ ផ្លូវរទេះនិងស្ពានថ្មឃុំពុំមានគំរោងសាងសង់ទេ។ ក្រៅពីនេះឃុំនៅមានគំរោងសង់ស្ពានឈើអោយបាន ចំនួន៣ស្ពានបន្ថែមពីលើស្ពានឈើដែលមានស្រាប់ចំនួន ៧ស្ពាន និងសង់លូឆ្លងផ្លូវអោយបានចំនួន១១ បន្ថែមទៀតពីលើលូដែលមានស្រាប់ចំនួន១0លូ នៅ១៥ឆ្នាំទៀត ព្រោះលូ និងស្ពានឈើដែលមានពុំទាន់អាចបំពេញតំរូវការនៃប្រើប្រាស់របស់ប្រជាពលរដ្ឋនៅឡើយ។

អំពីប្រពន្ធ័ទឹកនៅឃុំប៉ុងក្នុងឆ្នាំ២00៨គឺពុំមានមានប្រឡាយមេនិងប្រឡាយរង និងទ្វារទឹកនោះទេលើបញ្ហានេះឃុំតំរូវអោយសាងសង់ប្រឡាយ មេ៣ខ្សែមានប្រវែងសរុប២.៥0គ.ម និងប្រឡាយរង ៩ខ្សែមានប្រវែងសរុប ៣.00គ.ម។ សំរាប់១៥ឆ្នាំខាងមុខ ។រីឯទ្វារទឹកឃុំមានទិសដៅសង់អោយបានចំនួន១0សំរាប់ រយៈពេល១៥ឆ្នាំទៀត ព្រោះថាកន្លងមកពុំទាន់មានទ្វារទឹកសំរាប់ប្រើប្រាស់នោះទេ។

តារាងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

| **ប្រភេទហេដ្ឋារចនាសម្ព័ន្ធ** | **ប្រវែងផ្លូវឆ្នាំនេះ (គ.ម)** | **ប្រវែងផ្លូវ១៥ឆ្នាំ (គ.ម)** | **បំរែបំរួល** |
|---|---|---|---|
| ផ្លូវក្រាលកៅស៊ូ | 0 | ២៨.៥0 | ២៨.៥0 |
| ផ្លូវក្រាលគ្រួសក្រហម | ១១.៥0 | ១៦.00 | ៤.៥0 |
| ប្រវែងផ្លូវក្រាលដីស | 0 | 0 | 0 |
| ផ្លូវរទេះ/ថ្មើជើង | 0 | 0 | 0 |
| ប្រឡាយមេ | 0 | ២.៥0 | ២.៥0 |
| ប្រឡាយរង | 0 | ៣.00 | ៣.00 |
| ចំនួន ស្ពានថ្ម | 0 កន្លែង | 0 កន្លែង | 0 កន្លែង |
| ចំនួនស្ពានឈើ | ៧កន្លែង | ១0កន្លែង | ៣កន្លែង |
| ចំនួន ទ្វារទឹក | 0ទ្វារ | ១0ទ្វារ | ១0ទ្វារ |
| ចំនួនលូឆ្លងផ្លូវ | ១0លូ | ២១លូ | ១១លូ |

# ជំពូក ៣

# ផែនការប្រើប្រាស់ដីពេលអនាគត ឆ្នាំ ២០០៩ ដល់ ២០២២

## ៣.១ ស្ថានភាពដី សក្តានុពលដី និងតម្រូវការដី

### ៣.១.១ ស្ថានភាពដីទូទៅ និងសក្តានុពល

នៅក្នុងឃុំប៉ុង ធនធានដែលមានស្រាប់អាចផ្តល់នូវសក្តានុពលភាពដល់ការប្រើប្រាស់ដី និងអភិរក្ស អភិវឌ្ឍន៍ទៅលើធនធានទាំងនោះ អោយមាននិរន្តរភាព ដែលក្នុងនោះរួមមានដូចជា : ស្ថានភាពដី ដែលជាតំបន់ដីមានដីជាតិដែលជាប្រភេទដីក្រហម លាយនិងដីល្បាយខ្សាច់ពណ៌ខ្មៅ ដែលអំអោយផលទៅលើដំណាំយុទ្ធសាស្ត្រ និងការធ្វើកសិកម្ម សំរាប់ជួយទ្រទ្រង់ដល់ការប្រកបមុខរបររស់នៅ របស់ប្រជាពលរដ្ឋ ។ ដោយឡែកធនធានធម្មជាតិដីសំបូរបែបដែលផ្តល់នូវបរិស្ថានធម្មជាតិដ៏ល្អប្រសើរសំរាប់សត្វព្រៃ និងមច្ឆាជាតិរស់នៅ ព្រមទាំងពពួកជីវៈចំរុះ នៃប្រព័ន្ធអេកូឡូស៊ី ដែលធ្វើអោយតំបន់នេះបានផ្តល់នូវ សារៈប្រយោជន៍បំពេញអោយគ្នាទៅវិញទៅមក មិនត្រឹមតែប៉ុណ្ណោះធនធានដីសំបូរ បែបនេះបានជួយដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ក្នុងការដកហូតអនុផលព្រៃឈើ ដូចជា វល្លិ៍ ផ្តៅ ឬស្សីថបុរាណ និងប្រភេទឈើប្រណិត៧ដូចជាបេង នាងនួន ក្រញូង គគី ស្រឡៅ ដែលជាឈើសំរាប់សំណង់ និងគ្រឿងសង្ហារឹមជាដើម សំរាប់បំរើការអោយក្នុងតំបន់ និងក្រៅតំបន់ ។

### ៣.១.២ តម្រូវការដីតាមប្រភេទ

ដោយផ្អែកទៅលើអត្រាកំណើនរបស់ប្រជាពលរដ្ឋ មានការកើនឡើង ដូចនេះតម្រូវការនៃការប្រើប្រាស់ទៅលើធនធានត្រូវមានការសិក្សា និងធ្វើការពិចារណានៃធនធានដែលមាននៅក្នុងឃុំ ដោយរៀបចំគម្រោងផែនការទៅលើតម្រូវការពង្រីកដីលំនៅដ្ឋានសំរាប់សម្បទានសង្គមកិច្ច បានកំណត់នៅលើផ្ទៃដីស្ថិតនៅបណ្តោយផ្លូវជាប់ ព្រំប្រទល់ជាមួយនឹងឃុំភ្នំកុក និងមួយភាគទៀតជាដីស្រែ និងចំការដែលមានប្រព័ន្ធស្រោចស្រពពីទន្លេសេសាន ហូរចាក់តាមអូរតូចជាច្រើនមកតំបន់នេះ ។ ដោយយោងទៅតាមការពិភាក្សាជាមួយប្រជាជនឃុំបានរៀបចំផែនការ អនាគតសំរាប់ឃុំដោយបានគ្រោងដី សំរាប់ដីលំនៅដ្ឋានភូមិ ដែលមានទំហំ ៣០៥ ហិតតាសំរាប់រយៈពេល ១៥ ឆ្នាំ សំរាប់ជួយដល់ប្រជាជនដែលមានការខ្វះ ខាតដីសំរាប់ការតាំងទីលំនៅដ្ឋាន ដោយជ្រើសរើសកន្លែងដែលមានប្រភពទឹក គ្រប់គ្រាន់សំរាប់ប្រជាពលរដ្ឋក្នុងការប្រើ ប្រាស់នាពេលអនាគត ។

ព្រៃអារក្សជាតំបន់ព្រៃ ដែលប្រជាជនឃុំប៉ុង មានការគោរពបូរជា ជាទីសក្ការៈទៅតាមបែបប្រពៃណីទំនៀមទំលាប់ និងមានជំនឿយ៉ាងមុតមាំ លើអារក្ស អ្នកតា ម្ចាស់ទឹក ម្ចាស់ដី ដូចជាការសែនព្រេន ឬការបន់ស្រន់សុំអ្វីមួយដូចជាមានគ្រោះថ្នាក់ ឬឧប្បត្តិហេតុអ្វីមួយ ឬក៏កូនចៅញាតិសណ្តាន ដូចជាមានជំងឺ ឈឺគ្រុនក្តៅ ខ្យល់ចាប់រាករូសជាដើមដោយធ្វើការរំលឹកនឹកដល់ខ្មោចចាស់ព្រឹទ្ធាចាណាម្នាក់ ដែលរស់នៅគ្រប់គ្រងភូមិទាំងមូលមានឬទ្ធិបារមីអំណាចដឹកនាំ ពួកអ្នកស្រុកតែងបានសេចក្តីសុខ ហេតុដូចនេះឃុំបានរក្សាតំបន់នេះសំរាប់ជាកន្លែងបូជាសក្ការៈដែលរួមមាន ២កន្លែង សំរាប់ ភូមិបានហ្វាំងមានទំហំ ៥២២ ម៉ែត្រការ៉េ និងភូមិ បានប៉ុងមានទំហំ ២ ហិកតា ។

នៅក្នុងការពង្រីកដីវាលស្រែ របស់ឃុំប៉ុង គឺត្រូវបានចាប់អារម្មណ៏ទៅលើ ដីវាលស្រែដែលបានបោះបង់ចោល ក្លាយទៅជាវាលស្មៅ និងព្រៃរបោះដែល ដែលព្រៃឈើរិចរិល មិនមានការលូតលាស់ ដោយមានការផ្លាស់ប្តូរតំបន់នេះជាតំបន់ ដីស្រែវិញ ដោយឃើញថាតំបន់នេះអាចធ្វើស្រែបាន និងមានប្រភពទឹកគ្រប់គ្រាន់ សំរាប់ស្រោចស្រព ទាំងដីស្រែ និងចំការ និងម្យាងទៀតឃុំក៏បានគិតគូរផងដែរនូវបញ្ហាព្រំប្រទល់ ក្នុងករណីគម្រោង ផែនការពង្រីកដីកសិកម្ម ពេលអនាគមានការពាក់ពន្ធ័ និងព្រំប្រទល់ឃុំ នឹងឃុំ នឹងមានការកែសំរួលឡើងវិញបើមានលទ្ធភាព ទៅថ្ងៃអនាគត ដោយបានគ្រោងសំរាប់ដីកសិកម្មដែលមានទំហំ ៦៤២ ហិកតា ។

ដីសំរាប់វត្ត មួយកន្លែងដែលមានទំហំ ១ហិកតា ជាដីដែលឃុំបានគ្រោងសំរាប់ធ្វើវត្ត សំរាប់ប្រជាជនក្នុងការគោរពបូជា និងការអប់រំផ្នែកព្រះពុទ្ធសាសនា ដែលឃុំបានផ្តល់លទ្ធភាព និងជួយសំរួលដល់ប្រជាបលរដ្ឋនៅក្នុងឃុំមានឱកាសចូលរួម ពង្រីកលើការ ផ្សព្វផ្សាយតាមរយៈការអប់រំដល់ យុវជនដែលជាសរសរ ទ្រូងនៃប្រទេសជាតិអោយជៀសផុសពីអំពើខុសច្បាប់ទាំងឡាយ ។

ដីសាលារៀនឃុំក៏បានគ្រោងទុកចំនួន ២កន្លែងដែលមួយកន្លែង មានទំហំ ១ ហិកតា នៅជាប់ផ្លូវក្បែព្រៃកប់ខ្មោចភូមិបានហ្វាំង និងមួយកន្លែងទៀតមានទំហំ ៣ ហិកតានៅភូមិប៉ុងជាប់ផ្លូវ ហើយដីទាំងពីរកន្លែងនេះឃុំទុកសំរាប់សាងសង់វិទ្យាល័យ ដែលពីមុនដីនេះជាប្រភេទដីព្រៃរបោះរិចរិល។

ប៉ុស្តិ៍នគរបាល និងដីកងរាជអាវុធហត្ថនៃឃុំប៉ុង ឃុំបានគ្រោងរៀបចំ ដែលដីប៉ុស្តិ៍នគរបាលមានទំហំចំនួន ៣៩៤២ ម៉ែត្រការរ៉េ និង ដីកងរាជអាវុធហត្ថមានទំហំក្បាលដី ១ហិកតា ដីទាំង២កន្លែងនេះមានទីតាំងនៅជាប់ផ្លូវលំឃុំនៅក្បែព្រៃកប់ខ្មោចឃុំបានហ្វាំង ។ ដូច្នេះប្រភេទដីនេះ ស្ថិតនៅក្នុងក្របខណ្ឌ ជាដីឯកជនរបស់រដ្ឋ សំរាប់បំរើអោយនរគបាលឃុំ និងកងរាជអាវុធហត្ថ។

ដីសំរាប់តំកល់សព ដីនេះឃុំបានគ្រោងសំរាប់តំកល់សពដែលសពនេះបានស្លាប់មិនដឹងមូលហេតុហើយ បានប្រជាជនយកទៅតំកល់នៅនោះដើម្បីធ្វើបុណ្យ ដីនេះមានទំហំ ៣៧៤៤ម៉ែត្រការរ៉េហើយដីនេះបានផ្លាស់ប្តូរពីដីស្រែពីមុន ។

ដីសំរាប់ចាក់សំរាមនៅក្នុងឃុំប៉ុង ឃុំមានផែនការគ្រោងសំរាប់ពេលអនាគត ដីប្រភេទនេះជាដីសាធារះរបស់រដ្ឋ ដែលមានទំហំក្បាលដី ២ ហិកតា ដែលជាប្រភេទដីព្រៃ របោះ ហើយបានផ្លាស់ប្តូរមកជាដីសំរាប់ចាក់សំរាមវិញ។

ព្រៃដុះឡើងវិញ និងព្រៃរបោះគ្រប់គ្រងដោយសហគមន៏ ដីព្រៃនេះបានប្រែក្លាយពីដីព្រៃដុះឡើងវិញហើយមានបីតំបន់ ដីប្រភេទនេះឃុំប៉ុងមានគំរោងផែនការសំរាប់ការការពារព្រៃអោយដុះឡើងវិញ ហើយមានការគ្រប់គ្រងដោយសហគមន៏ខ្លួនឯងផ្ទាល់ តំបន់ទី ១ មានផែនការគ្រោងដែលមានទំហំ ៨១ ហិកតា និងតំបន់ទី ២ មានការគ្រោងដែលមានទំហំ ២៤១ ហិកតា និងតំបន់ទី ៣ មានការគ្រោងទំហំ ៥២៧ ហិកតា ដែលតំបន់ទី ៣នេះបានប្រែក្លាយពីតំបន់ព្រៃស្រោងសើម ហើយដីនេះស្ថិតនៅក្នុងក្របខណ្ឌជាដីសាធារណៈរបស់រដ្ឋមិនអាចយកដីទាំងនេះប្រើប្រាស់សំរាប់ជាប្រយោជន៏ ឯកជនឡើយ ។

ព្រៃស្រោងសើម និងព្រៃរបោះសំរាប់តំបន់អភិរក្សសត្វព្រៃគឺ ជាកត្តាចំបងមួយសំរាប់ការការពារថែរក្សាអភិរក្ស និងអភិវឌ្ឍន៏ទៅលើធនធានធម្មជាតិ នៅក្នុងការប៉ាន់ប្រមាណទៅលើការកើនឡើងនៃដីព្រៃ និង

សត្វព្រៃដែលមានការជួយគាំទ្រ និងការថែរក្សាដោយសហគមន៍ដែលមានទំហំ ៦០១ ហិកតា ដីព្រៃនេះគឺជាដីព្រៃស្រោងសើម ។

## ៣.២ ការបែងចែកដីតាមតម្រូវការប្រើប្រាស់

### ៣.២.១ ការវិភាគអន្តរអំពើ

ការគ្រប់គ្រងនិងបែងចែកសំរាប់ការប្រើប្រាស់ដី មានកត្តាដែលធ្វើអោយមានការផ្តល់នូវ ផលប្រយោជន៍ និងមាននិរន្តរភាពហើយនឹង មានការប៉ះពាល់ទៅលើផ្នែកមួយចំនួនដូចជា សេដ្ឋកិច្ច សង្គមកិច្ច និង បរិស្ថាន ដែលក្នុងនោះមានដូចជា :

ការប្រែប្រួលព្រៃចំរុះស្រោង និងរបោះប្រែក្លាយទៅជាដីលំនៅដ្ឋានសំរាប់សម្បទានសង្គមកិច្ចវាជាការជួយដល់ប្រជាពលរដ្ឋដែលខ្វះខាតដីសំរាប់សង់លំនៅដ្ឋាន កត្តានេះវាជំរុញអោយប្រជាពលរដ្ឋនាពេលបច្ចុប្បន្ន ក៏ដូចជានកូនចៅជំនាន់ក្រោយមិនមានចំណាកស្រុក ដែលអ្នកទាំង នេះជាធនធានសំរាប់ការអភិវឌ្ឍ ឃុំរបស់ខ្លួននាពេលខាងមុខ ។

ការប្រែប្រួលពី ដីព្រៃរបោះរិចរិល ទៅជាដីស្រែសំរាប់ការបង្កបង្កើនផល នេះជាការពង្រីក លើវិស័យកសិកម្ម វាជាកត្តាអំណោយផល ដល់ការបង្កើននូវផលិតផល ក៏ដូចជា សេដ្ឋកិច្ច ក្នុងមូលដ្ឋាន។ នៅក្នុងបរិបទនេះ ការប្រែប្រួលប្រភេទដីប្រសិនបើជាប្រភេទព្រៃរបោះរិចរិលមកជាដី សំរាប់ធ្វើកសិកម្ម នោះវាជាមោទនៈភាពសំរាប់ការពង្រីកលើការងារធ្វើស្រែដែលផ្តល់ផលប្រយោជន៍ក្នុងការរកប្រាក់ចំណូលដើម្បីកាត់ បន្ថយភាពក្រីក្រ។

ការអភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធ នៅក្នុងមូលដ្ឋានឃុំ គឺជា កត្តាផ្តល់នូវផលប្រយោជន៏ យ៉ាងច្រើនដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានដែលក្នុងនោះមានដូចជា :

- ការសាងសង់ផ្លូវគឺជាការសំរួលដល់ការធ្វើដំណើរ និង ចរាចរណ៏គ្រប់ប្រភេទ ហើយនិងចូលរួមក្នុងការកាត់បន្ថយការចំណាយ ទៅលើការងារដឹកជញ្ជូន ។ ការអភិវឌ្ឍន៏នេះថ្វីត្បិតតែមានការដោះស្រាយ និងហេតុប៉ះពាល់ខ្លះៗក៏ដោយ ប៉ុន្តែវាផ្តល់នូវផលប្រយោជន៏ច្រើនដល់ប្រជាជនប្រើប្រាស់ ។

-ការសាងសង់ប្រឡាយដើម្បីធានាដល់ការស្រោចស្រព្វក៏ជាកត្តាផ្តល់នូវសារៈប្រយោជន៏ ក្នុងការបង្កើន នូវប្រាក់ចំណូល តាមរយៈការបង្កបង្កើនផល និង ដំណាំរួមផ្សំ។ នៅក្នុងឃុំប៉ុង តម្រូវការប្រើប្រាស់ទឹកសំរាប់ស្រោចស្រព្វ គឺ ជាកត្តាសំខាន់ ថ្វីត្បិតតែការពង្រីកប្រពន្ធ័ស្រោចស្រព្វនេះជួបការលំបាកយ៉ាងណាក៏ដោយក៏ឃុំនៅ តែព្យាយាមរកវិធីសាស្រ្តដោះស្រាយ និង ជំរុញអោយមាននិរន្តរភាពលើការងារនេះ ។

ដោយឡែកចំពោះការពង្រីកវិស័យអប់រំ ដោយផ្តោតទៅលើ ការពង្រីកអាគារសិក្សា និង សាលាគឺជាការចាំបាច់បំផុតសំរាប់ការបង្កើនធនធានមនុស្សនៅក្នុងមូលដ្ឋាន។ បច្ចុប្បន្នទោះបីឃុំមានការខ្វះខាតដីសំរាប់បង្កើតសាលាថ្មីសំរាប់ថ្នាក់បឋមសិក្សា និង អនុវិទ្យាល័យប៉ុន្តែជាអាទិភាពនៅតាមសាលាចាស់ នៅមានដីដែលអាចសាងសង់អាគារសិក្សាបន្ថែមបាន ។ រីឯសាលាមតេយ្យដោយមើលឃើញការលំបាកសំរាប់កុមារ ដែលគ្មានលទ្ធភាពក្នុងការសិក្សា នៅទីកន្លែងឆ្ងាយគឺជាអាទិភាពឃុំត្រូវព្យាយាមរកដំណោះស្រាយអោយខានតែបាននៅតាមបណ្តុភូមិគោលដៅព្រោះវាមានសារៈសំខាន់និងជាមូលដ្ឋានគ្រឹះនៃការបណ្តុះបណ្តាល នឹងការបំពាក់បំប៉នចំណេះដឹងដល់អនក្ខរៈជនក្នុងមូលដ្ឋាន។

### ៣.២.២ ផែនទីប្រើប្រាស់ដីពេលអនាគត

### ៣.២.៣ ការបរិយាយការប្រើប្រាស់តាមក្បាលដី

ការប្រើប្រាស់ដីនៅក្នុង ឃុំប៉ុងត្រូវបានបែងចែក ទៅតាមគោលការណ៍ មួយចំនួន ដែលមានលក្ខណៈជាសត្យានុម័តហើយបានអនុលោមទៅតាមមុខនាទី ដូចខាងក្រោម :

៣.២.២.១ ដីលំនៅដ្ឋានសំរាប់សម្បទានសង្គមកិច្ច

-ក្បាលដី ៦៧០០

ការប្រើប្រាស់សំរាប់ដីលំនៅដ្ឋានឬដីភូមិមានទំហំ៣០៥ហិចតា គឺជាដីដែលផ្តល់នូវសក្តានុពលទៅលើការសាងសង់លំនៅដ្ឋានដោយមាន រួមផ្សំ ដូចជា ដូង ស្វាយ ខ្នុរ ទឹកដោះគោ ទៀប មាន ល្មុត ល្ហុង ចេក ។ល។ ជាមួយគ្នានេះដែរប្រភេទដីលំនៅដ្ឋានអាចមានដីស្រែដែលមានលក្ខណៈជាទីសំណាបឬជាដីសំរាប់ដាំដំណាំរយៈពេលខ្លី ដូចជាពោតសណ្តែក ត្រឡាច ននោង ល្ពៅ អំពៅ ដំឡូង ស្ពៃគ្រប់ប្រភេទ............ ។

៣.២.២.២ ដីកសិកម្ម

-ក្បាលដី ២១១៤

ការប្រើប្រាស់ដីសំរាប់ដីស្រែនៅក្នុងឃុំប៉ុងមានទំហំ៦៤២ហិចតា គឺមានការចាត់ថ្នាក់តែមួយប្រភេទប៉ុណ្ណោះដែលប្រជាពលរដ្ឋសព្វថ្ងៃ ធ្វើស្រែតែមួយរដូវ គឺស្រូវស្រែវស្សាដែលតែងតែពឹងផ្អែកតែលើរបបទឹកភ្លៀងទាំងស្រុង ។ ការប្រែប្រួលក៏ដូចជាការកើនឡើងនៃប្រភេទដីស្រែ ចំការ នេះគឺជាការពង្រីកទៅលើដីព្រៃរបោះរិចរិល ដែលប្រភេទដីព្រៃនេះជាប្រភេទដីអាចរៀបចំធ្វើស្រែ និងចំការ ដែលដីប្រភេទនេះបានទុកចោលអោយនៅទំនេ ហើយត្រូវបានធ្វើការរៀបចំកែលំអរឡើងវិញដោយធ្វើការ កែលំអរទៅតាមលក្ខណៈបច្ចេកទេសកសិកម្មដំណាំស្រូវដល់ប្រជា ពលរដ្ឋដើម្បីផ្តល់ឳកាសដល់ពួកគាត់ចូលរួមក្នុងការបង្កើននូវទិន្នផលនៅក្នុងមូលដ្ឋាន។ ផ្អែកទៅតាមស្ថានភាពដី ជាដីព្រៃរបោះរិចរិល បច្ចុប្បន្នកន្លែងនេះមានសណ្ឋានជាដីទទួលបាននូវប្រព័ន្ធស្រោចស្រព្វដែលសមស្រប អាចធ្វើការផ្លាស់ប្តូរសំរាប់ដំណាំស្រូវវស្សា និងចំការហើយចំពោះដីប្រភេទនេះយើងត្រូវធ្វើការផ្ទៀងផ្ទាត់ អោយបានត្រឹមត្រូវដើម្បីជៀសវាងការរំាតយកដីពីសំណាក់ជនខិលខូចមួយចំនួន ដែល កំពុងឆ្លៀតឱកាស ។

៣.២.២.៣ ព្រៃអារក្ស

-ក្បាលដី ៣៧៤០

ព្រៃអារក្សប្រើសំរាប់គោរពតាមទំនៀមទំលាប់ប្រពៃណីមានទំហំ ០,៣៧ហ.ត បានមកអំពីមួយផ្នែកនៃព្រៃស្រោងសើម ។ ការប្រតិបត្តិនៅតំបន់នេះស្រដៀងគ្នានឹងតំបន់អភិរក្សសត្វព្រៃដែរ ពោលគឺការប្រើប្រាស់ទៅបានលុះត្រាគោរពតាមប្រពៃណីតំនៀមទំលាប់នៃជនជាតិនៅក្នុងតំបន់ ដូចជាការបន់ស្រន់ សែនព្រេនិងតំណមផ្សេងៗ មិនអនុញ្ញាតអោយចូលព្រៃរុករកភោគផលផ្សេងៗដែលមាននោះឡើយ ។

៣.២.២.៤ ព្រៃសហគមន៏(សហគមន៏ព្រៃឈើ)

-ក្បាលដី ៣៧១០

ព្រៃដុះឡើងវិញ និងព្រៃចំរុះ(ស្រោងនិងរបោះ) គ្រប់គ្រងដោយសហគមន៏ ដីព្រៃប្រភេទនេះជាដីសាធារណៈរបស់រដ្ឋមានទំហំ៨៤៩ហិចតា ដែលសំបូរទៅដោយជីវៈចំរុះ និងមានប្រភេទឈើប្រណិតៗដូចជា ស្រឡៅ នាងនួន បេង

កកោះ ក្រញូង គគី ធ្នឹក ... ។ល។ ដែលតំបន់នេះទាមទារ គឺត្រូវអោយមានការថែរក្សាអោយបានគង់វង្ស ដូច្នេះឃុំមាន គោលបំណងធ្វើការរៀបចំនូវផែនការក្នុងការ ការពារ ថែរក្សា អភិរក្ស និងអភិវឌ្ឍន៏ទៅ លើធនធានទាំងនេះ ដើម្បីផ្តល់នូវផលប្រយោជន៏ ក្នុងការបង្កើនប្រាក់ចំណូលសំរាប់ប្រជាពលរដ្ឋតាមរយៈការប្រើប្រាស់ប្រកបដោយនិរន្តរភាព ពីសំណាក់សហគមន៏ដែលរស់នៅក្នុងតំបន់នោះ ។

៣.២.២.៥ តំបន់អភិរក្សសត្វព្រៃ

-ក្បាលដី ៦៦០០

-ព្រៃស្រោងសើម និងព្រៃរបោះសំរាប់តំបន់អភិរក្សសត្វព្រៃមានទំហំ៦០១ហិចតាដីព្រៃនេះជាដីដែលសំបូរទៅដោយដើមឈើដុះតូចធំមានពណ៌ខៀវខ្ចីស្រស់គ្រប់រដូវ ។ កន្លែងនេះជាកន្លែងដែលសត្វព្រៃចូលចិត្តរស់នៅព្រោះមានប្រភពទឹក និង ច្រាបដែល អំណោយផលខ្លាំង ក្នុងការរស់នៅដូចជាពពួកសត្វ ឈ្លូស ប្រើស ទន្សាយ ខ្លាត្រី អាញ៉ី កាំប្រមា និងពពួកសត្វស្លាបផងដូច្នេះជាគោលការណ៏ តម្រូវការរបស់ឃុំ ត្រូវតែការពារថែរក្សាទុកសំរាប់ជាកេរ្តិ៍តំណែល និង ភស្តុតាងដល់កូនចៅជំនាន់ក្រោយបានស្គាល់ និងឃើញ ។

កាប្រើប្រាស់ដីសំរាប់ការសាងសង់ផ្លូវថ្នល់ ក៏មានបញ្ហាខ្លះដែរប៉ុន្តែអាចដោះស្រាយបានព្រោះថា ផ្លូវ ដែលកើតឡើង គឺជាការផ្តើមចេញពីប្រជាជនផ្ទាល់ដែលជាអ្នកធ្វើអោយកើតមានផ្លូវជាដំបូង ហើយឃុំក៏លើកគម្រោងអភិវឌ្ឍទោតាមការស្នើរឡើងពីសំណាក់ប្រជាពលរដ្ឋ។ បច្ចុប្បន្នការអភិវឌ្ឍន៏ទៅលើហេដ្ឋារចនាសម្ពន្ធ័ ផ្លូវថ្នល់ក្នុងឃុំ គឺអនុវត្តទៅលើផ្លូវចាស់មានស្រាប់ ដូច្នេះដំណោះស្រាយអាចដោះស្រាយបាន ។

<u>តារាងតម្រូវការនៃការប្រើប្រាស់ដីពេលអនាគត</u>

| **ការប្រើប្រាស់ដីថ្មី** | **លេខកូដក្បាលដី** | **ក្រឡាផ្ទៃឆ្នាំនេះ (ហិចតា)** | **ក្រឡា ផ្ទៃ សំរាប់ ១៥ឆ្នាំខាងមុខ (ហិចតា)** | **បំរែបំរួល (ហិចតា)** |
|---|---|---|---|---|
| ដីលំនៅដ្ឋានសំរាប់សម្បទានសង្គមកិច្ច | F6700 | ៦៨ | ៣០៥ | ២៣៧ |
| ដីកសិកម្ម | F2114 | ១៣១០ | ១៩៥២ | ៦៤២ |
| ព្រៃអារក្ស | F3740 | ១ | ១ | 0 |
| ព្រៃសហគមន៏(សហគមន៏ព្រៃឈើ) | F3710 | 0 | ៥២៧ | ៨៤៩ |
| តំបន់អភិរក្សសត្វព្រៃ | F6600 | 0 | ៦០១ | ៦០១ |
| **សរុប** | | **១៣៧៩** | **៣៣៨៦** | **២៣២៩** |

ឃុំប៉ុង ថ្ងៃ ...05...ខែ...04.....ឆ្នាំ២០១០

**មេឃុំ**

គិ_ខាំ

**បានឃើញ និង ពិនិត្យត្រឹមត្រូវ**

គោរពជូន ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្ត

និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តរតនគិរី

"ដើម្បីមេត្តាពិនិត្យ និងសំរេច"

វើនសៃ ថ្ងៃ ..06....ខែ..04....ឆ្នាំ ២០១០

**អភិបាលនៃគណៈអភិបាលស្រុក**

**និងជាប្រធានក្រុមការងារដីរដ្ឋ**

**ស្រុកវើនសៃ**

ជុំ_ចិល

**បានឃើញ និង ឯកភាព** ។

រតនគិរី ថ្ងៃ .21...ខែ..05.....ឆ្នាំ ២០១០

**អភិបាលនៃគណៈអភិបាលខេត្ត**

**និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ**

**ខេត្តរតនគិរី**

ប៉ាវ_ហមផាន

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ១៖  ការពិពណ៌នាអំពីស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

ឧបសម្ព័ន្ធ២៖  ស្ថានភាពនៃការគ្រប់គ្រង  និងកាន់កាប់ដីបច្ចុប្បន្ន

ឧបសម្ព័ន្ធ៣៖  បញ្ហាពាក់ព័ន្ធក្នុងការប្រើប្រាស់ដី

ឧបសម្ព័ន្ធ៤៖  ក្របខ័ណ្ឌនៃការអភិវឌ្ឍន៍

ឧបសម្ព័ន្ធ៥៖  បញ្ជីគំរោង

ឧបសម្ព័ន្ធ៦៖  ផែនទីប្រើប្រាស់ដីលំអិតនៅក្នុងឃុំ

ឧបសម្ព័ន្ធ៧៖  ផែនទីប្រើប្រាស់ដីសាមញ្ញនៅក្នុងឃុំ

ឧបសម្ព័ន្ធ៨៖  ផែនទីប្រើប្រាស់ដីអនាគតនៅក្នុងឃុំ  ឆ្នាំ២០០៩-២០២២

## ឧបសម្ព័ន ១

## ការពិពណ៌នា អំពីស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

- **ដីលំនៅដ្ឋានភូមិ:**

**ដីភូមិលាយសួនដំណាំ :**

ដីភូមិលាយសួនដំណាំ នៅក្នុងមូលដ្ឋានឃុំប៉ុងគឺជាដីស្ថិតនៅតាមដងផ្លូវ និងជាប់ជាមួយទន្លេសេសាន ដែលមានស្ថានភាពជាដីទីជំរាល និង ដោយការចាក់បំពេញ ធ្វើជាភូមិដ្ឋាន ។ ជាមួយគ្នានេះដែរដីភូមិទាំងនេះត្រូវបានដាំនូវដំណាំរួមផ្សំ នានាជាច្រើន ដូចជា ស្លែ ននោង ត្រឡាច ល្ពៅ ស្លឹកគ្រៃ ខ្ញី ជី ត្រប់ ម្រិច ចេក ដូង ដំឡូង ស្វាយ ខ្នុរ អំពៅ និងដំណាំរួមផ្សំមួយចំនួនទៀត........។ ល។ ដំណាំភាគច្រើនស្ថិតនៅ ជាប់តគ្នាតាមបណ្តោយផ្លូវ ជាប់ដងទន្លេ សេសាន ។ ដីលំនៅដ្ឋាន នីមួយៗមានតំហំក្បាលដី ចាប់ពី ១៥មែត្រ X ៥០ ម៉ែត្រ ទៅ ៣០ ម៉ែត្រ X ១០០ ម៉ែត្រ ។ លំនៅដ្ឋាននៅឃុំនេះជាប្រភេទលំនៅដ្ឋានចំរុះឈើ (ប្រភេទឈើអារ) ប្រក់សង្កសី ស្លឹក ខ្លះសង់ជាប់ នឹងដី ខ្លះខ្ពស់ផុតពីដី តាមបែបទំនាមទំលាប់ប្រពៃណីខ្មែរឡាវ និងបងប្អូនជនជាតិដើមភាគតិចនៅទីនោះ ។ ប្រភេទដីភូមិលាយសួនដំណាំរបស់បងប្អូនជនជាតិដើមភាគតិចកមានសង់ផ្ទះនៅតាមចំការរបស់ គាត់ដែរ តែភាគតិចណាស់ ប្រហែល ១ភាគរយនៃបងប្អូនតែប៉ុណ្ណោះ ។

**ដីភូមិលាយស្រែ :**

ដីភូមិលាយស្រែ គឺជាដីដែលភាគច្រើនជាដីភូមិដែលស្ថិតនៅដាច់ៗពីគ្នា ហើយនៅក្នុងរង្វង់ដីភូមិ មានដីស្រែផ្នែកខាងក្រោយនៃដីភូមិ ។ ចំពោះដីស្រែក្នុង ភូមិគេច្រើន ប្រើសំរាប់ធ្វើទីសំណាប ម្យ៉ាងវិញទៀតចំពោះអ្នកមានដីភូមិជាប់ផ្លូវគឺអាចប្រើប្រាស់ដី ស្រែសំរាប់ដាំដំណាំនានានៅរដូវប្រាំង ដូចជា,ពោត,សណ្តែក,ត្រសក់ ននោង ត្រឡាច ល្ពៅ ស្លែ ឆៃថាវ ម្ទេស ឃ្លោក ដំឡូង ចេក ស្លឹកងប់ ស្លឹកបាស់ .........។ ល ។ ស្រែដែលនៅក្នុងដីភូមិ ច្រើនមានទំហំ តូចៗ ហើយមានទំហំ ពី ៣០ X ១០០ ម៉ែត្រក្រឡា និង ៥០ X ១០០ ម៉ែត្រក្រឡា ភាគច្រើនស្ថិតផ្នែកខាងក្រោយនៃដីភូមិ ។ ដីភូមិលាយស្រែ ច្រើនស្ថិតនៅដាច់ពីគេ ព្រោះជាដីភូមិដែលគ្រួសារបែកផ្ទះថ្មី ។

ដីស្រែក្នុងភូមិ បច្ចុប្បន្នត្រូវបានប្រើប្រាស់ ធ្វើជាទីសំណាប និងដាំនូវដំណាំរយៈពេលខ្លីដូចជា ពោត,សណ្តែក និង បន្លែ គ្រប់ប្រភេទ ប៉ុន្តែទៅថ្ងៃអនាគត ដីនេះនឹងក្លាយជាដីភូមិ ដែលត្រូវឪពុក ម្តាយចែកអោយកូន ។ ដូច្នេះតាមការពិនិត្យសក្តានុពល នៃការប្រើប្រាស់ ដី ឃើញថា គ្មានតុល្យភាពទៅនិង កំណើន និងសេចក្តី ត្រូវការរបស់ប្រជាពលរដ្ឋឡើយ គឺបង្កើនផលិតភាពលើវិស័យកសិកម្មអោយបានល្អប្រសើរជាងមុន (បញ្ចូល បច្ចេកវិទ្យាថ្មី) ។

- **ដីស្រែវស្សា :**

**ដីស្រែវស្សា ( ស្រូវសន្ទូង ) :**

ដីស្រែវស្សានៅឃុំប៉ុងត្រូវបានប្រើប្រាស់ ក្នុងការធ្វើស្រែមួយរដូវ គឺស្រែ វស្សា ដោយពឹងផ្អែកទៅលើទឹកភ្លៀង។ ប៉ុន្តែស្រែមួយចំនួនដែលស្ថិតជិតប្រភពទឹក មានលក្ខណៈល្អប្រសើរដោយមាន ទឹកអូរ ដែលមានប្រភព ហូរពីទន្លេសេសាន នៅពេល ជួបគ្រោះរាំងស្ងួតរយៈពេលខ្លី ។ ចំណែកស្រូវនៅក្នុងឃុំឃើញថាប្រជាជន មិននិយមប្រើប្រាស់ជីគីមីទេ គឺពួកគាត់ប្រើប្រាស់ជីធម្មជាតិ ដូចជា ជីកំប៉ុស្តិ៍ និងលាមកសត្វជាដើម ដីស្រែវស្សានៅឃុំប៉ុង គេអាចធ្វើបានផលពី ១៥០០ គ.ក្រ ទៅ ២០០០ គ.ក្រ ក្នុងមួយហិចតា ដោយប្រើប្រភេទស្រូវធ្ងន់មាន: នាងនូ,ក្រមួនស សូមាលី ប្រភេទស្រូវស្រាល : នាងខ្ទួន ក្រចកចាប ប្រវិកស ស្រូវ ៥០០ គ្រាប់ ។ ប្រភេទស្រូវកណ្តាល : ស្រូវដំណើប ចំបើងលឿង ប្រកិន ផ្កាខ្ញី ។ ដីស្រែនៅឃុំប៉ុង សរុប ៨៤៨.៤៨ ហិកតា ចំពោះពេលវេលាក្នុងការធ្វើស្រែ មានរយៈពេល ៧ ខែ ពីខែឧសភា ដល់ ខែវិច្ឆិកា។ ដីស្រែវស្សាបច្ចុប្បន្ន ក៏នៅពុំទាន់ បំរើបាននៅសេចក្តីត្រូវការប្រើប្រាស់អោយអស់លទ្ធភាពនៅឡើយ ព្រោះវា នៅមានបញ្ហាចោទ លើការខ្វះទឹក ពិសេសការរាំងស្ងួត ដែលជាកត្តា ធ្វើអោយប្រជាជន នៅឃុំប៉ុងធ្វើស្រែមិនបានផល ឬ ធ្វើហើយមានការស្វិតខូច មិនទទួលបាននូវទិន្នផលខ្ពស់ ។ ករណីនេះដោយសារការខ្វះប្រពន្ធ័ធារាសាស្ត្រ ក្នុង ការជួយសង្គ្រោះ ពេលខ្វះទឹក នៅកូនរដូវប្រាំង ឬការរាំងស្ងួត ។

- **ដីកសិកម្មពនេចរ :**

ដីកសិកម្មពនេចរមានផ្ទៃដីសរុប៤៦២.១៦ហ.តសំដៅលើដីចំការផ្លាស់វេនដំណាំដែលក្នុងនោះរួមមានចំការដំណាំស្រូវនិងដំណាំរួមផ្សំផ្សេងៗទៀតរួមមានបន្លែបង្កាគ្រប់ប្រភេទនិងមិនមានអោយដាំដំណាំដើមឈើហូបផ្លែនិងដំណាំយុទ្ធសាស្ត្រទេ ព្រោះដីចំការវិលជុំនេះពួកគាត់ធ្វើតែរយៈពេល២ឆ្នាំប៉ុណ្ណោះ ដែលក្នុងឆ្នាំទី១ដំណាំស្រូវទទួលបានលទ្ធផលខ្ពស់ ចំណែកនៅឆ្នាំទី២ផលស្រូវថយចុះបើធៀបនឹងឆ្នាំទី១។ បន្ទាប់ពីនោះគឺពួកគាត់បន្តទៅធ្វើ នៅកន្លែងផ្សេងទៀត ដែលដីនោះបានបោះបង់អស់រយៈពេល ៥ឆ្នាំមុននេះ បានក្លាយជាដីដុះដើមឈើឡើងវិញ និងមានជីវជាតិ ។

ដីកសិកម្មពនេចរគឺសំរាប់បងប្អូនជនជាតិភាគតិចដែលការគ្រប់គ្រងនិងកាន់កាប់ទៅតាមជំនឿ និងប្រពៃណីរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៏ ។ចំការប្រភេទនេះច្រើកាប់នៅចំងាយពី២គ.មទៅ៣គ.មពីភូមិ ហើយចំការប្រភេទនេះពេលអនាគតនឹងក្លាយទៅជាដីលំនៅដ្ឋានអចិន្ត្រៃយ៏របស់ប្រជាពលរដ្ឋនៅក្នុងឃុំ។

- **កន្លែងកប់ខ្មោច :**

ភាគច្រើនជាដីដែលពុំសូវមានប្រភេទឈើធំៗឬព្រៃក្រាស់នោះទេ វាសំបូរកូនឈើតូចៗដែលការប្រើប្រាស់ធនធានទាំងនោះពុំមែនជាប្រយោជន៍ធំដុំរបស់ប្រជាជនឡើយ ។ដីកប់ខ្មោចសំរាប់តែបញ្ចុះសព្វតាមប្រពៃណីនៃជនជាតិនៅក្នុងតំបន់ ដែលពួកគេពុំមានការប្រកាន់យកនូវប្រពៃណីណាផ្សេងទៀត ។ការប្រើប្រាស់បន្ទាប់បន្សំផ្សេងទៀតអាចប្រព្រឹត្តទៅបានក្នុងទំហំដី៧.០៤ហ.ត លើកលែងតែកាប់រានយកដីធ្វើស្រែឬចំការ ។

- **ព្រៃស្រោងស្ងួត :**

ព្រៃស្រោងស្ងួតជាប្រភេទព្រៃញាតមានឈើធំៗនិងមានច្រើនស្រទាប់ហើយស្លឹករបស់វាមិនអាចរក្សាបានពេញមួយឆ្នាំពោលគឺវាងាប់និងជ្រុះជាបន្តបន្ទាប់ហើយព្រៃប្រភេទនេះច្រើនមាននៅតំបន់ភ្នំ និងនៅតាមមាត់ស្ទឹង ទន្លេ ។

- **ព្រៃល្បោះ :**

ព្រៃនេះរួមបញ្ចូលព្រៃរបោះចំរុះស្ងួត និងប្រភេទព្រៃ DIPTERCARP ស្ងួត ។ព្រៃរបោះជ្រុះស្លឹកស្ទើរតែទាំងស្រុងនៅរដូវប្រាំង ។ព្រៃប្រភេទនេះងាយទទួលការឆេះ បើប្រៀបធៀបនឹងប្រភេទព្រៃផ្សេងទៀត ។លក្ខណៈធម្មជាតិព្រៃ DIPTERCARP ស្ងួតមានភាពរហាលឬចំហរ ប្រសិនបើពុំមានការរំខាន ព្រៃរបោះ អាចមានគំរបកន្ទ្រោមស្លឹកត្រឹមតែ៤០%ដី និងវាលស្មៅអាចមានឥទ្ធិពលសំខាន់លើការសំគាល់ព្រៃប្រភេទនេះ ។នៅរដូវ ប្រាំងវាមានការពិបាកក្នុង ការញែកប្រភេទព្រៃរបោះចេញពីព្រៃគម្លោច ។

- **ព្រៃល្បោះស្ងួត :**

ព្រៃនេះស្រដៀងនឹងព្រៃល្បោះដែរ តែមានតែប្រភេទល្បោះស្ងួតនិងប្រភេទព្រៃ DIPTERCARP ស្ងួតតែប៉ុណ្ណោះ ។វាជ្រុះស្លឹកស្ទើរតែទាំងស្រុងនៅរដូវប្រាំង ហើយងាយទទួលការឆេះ បើប្រៀបធៀបនឹងប្រភេទព្រៃផ្សេងទៀត ។

- **ព្រៃចំរុះ(ល្បោះនិងស្រោង) :**

ព្រៃប្រភេទនេះជាការរាប់បញ្ចូលព្រៃស្រោងនិងប្រភេទឈើនៃព្រៃរបោះ ហើយភាគរយនៃព្រៃស្រោងប្រែប្រួលពី៣០%ទៅ៧០% ។ព្រៃចំរុះមានពណ៌បៃតងពេញមួយឆ្នាំទោះបីជាព្រៃរបោះមានច្រើនលើសលប់ក៏ដោយ

- **ព្រៃដុះឡើងវិញ :**

ព្រៃដុះឡើវិញគឺជាព្រៃបានមកពីស្រទាប់កូនឈើតូចៗដែលដុះឡើងវិញជាថ្មី បន្ទាប់ពីបានកាប់រានធ្វើចំការពនេចរអស់មួយរយៈពេលមក អាចនិយាយបានថាជាតំបន់នៃដំណុះព្រៃចាស់ៗឡើងវិញ ។

- **វាលស្មៅ :**

វាលស្មៅវាមានលក្ខណៈដូចគ្នានឹងព្រៃដុះឡើងវិញដែរ គឺសំដៅលើដីស្រែដែលបោះបង់យូរឆ្នាំហើយប្រភេទដីនៅទីនោះមិនអំណោយផលដល់ការដុះលូតលាស់នៃប្រភេទកូនឈើ វាបានដុះស្មៅក្នុងអំឡុងពេលបោះបង់ពី៥ឆ្នាំទៅ៧ឆ្នាំ ។

- **ចំការបោះបង់ដុះស្មៅ:**

ចំការបោះបង់ដុះស្មៅក៏ដូចគ្នានឹងវាលស្មៅដែរ ពោលគឺសំដៅទៅលើចំការពនេចរដំណាំស្រូវចំការនៅរដូវវស្សា ក្នុងអំឡុងពេលបោះបង់ពី៥ ទៅ៧ឆ្នាំ បានដុះស្មៅនិងដើមឈើតូចៗជាច្រើន ខុសគ្នាត្រង់ថាវាលស្មៅគឺមាននៅដីស្រែបោះបង់ ឯចំការបោះបង់ដុះស្មៅគឺសំដៅលើដីចំការបោះបង់។

- **ព្រៃគម្លោចៈ**

ព្រៃគម្លោចគឺជាដីមិនមែនព្រៃដែលរួមមានព្រៃគម្លោចបៃតងជានិច្ច និងព្រៃគម្លោចស្ងួត។ព្រៃគម្លោចបៃតងជានិច្ច ជាការដុះលាយនៃពពួកចុល្លព្រឹក្សក្រាស់ វាលស្មៅ និងដើមឈើដែលគំរបកន្ទ្យោមស្លឹកក្រោម២០%។ ព្រៃប្រភេទនេះឃើញមានភាគច្រើននៅតំបន់ដីរាក់ៗ នៅលើកំពូលភ្នំក្រោមលក្ខខ័ណ្ឌអាកាសធាតុ ឬជាលទ្ធផលនៃការប្រើប្រាស់ដីមិនមាននិរន្តរភាព។ព្រៃប្រភេទនេះអាចក្លាយទៅជាព្រៃធំៗឡើងវិញបាន។

- **ចំការបោះបង់ដុះព្រៃគម្លោច :**

ចំការបោះបង់ដុះព្រៃគម្លោច គឺជាចំការចាស់ដែលបោះបង់ក្នុងរយៈពេលពី៥ទៅ៧ឆ្នាំ វាបានដុះចេញជាដើមឈើតូចៗជាច្រើនលាយឡំគ្នា ដែលដើមឈើនោះអាចក្លាយព្រៃធំៗបាន។

- **ព្រៃគម្លោចលាយដើមឈើធំមួយៗ :**

សំដៅលើពពួកព្រៃធម្មជាតិដែលមានស្រាប់ជាអចិន្ត្រៃយ៍ ពុំមែនដុះលើចំការបោះបង់ណាមួយ ព្រៃប្រភេទនេះមានដើមឈើធំៗដុះលាយឡំគ្នានឹងបណ្តាឈើតូចៗជាច្រើនទៀត។

- **បឹង :**

ច្រើនមានពីធម្មជាតិ ជាផ្ទៃទឹកសំរាប់ជាជំរកនិងរក្សានូវពពួជត្រីជាច្រើនប្រភេទដែលមាននៅក្នុងតំបន់។ ជាធម្មតាបឹងច្រើនរាក់និងរីងស្ងួតនៅរដូវប្រាំង បង្កការលំបាកចំពោះការរស់នៅនៃសត្វត្រីហើយប៉ះពាល់ផងដែរដល់ការប្រើប្រាស់របស់មនុស្ស។

- **អូរ ស្ទឹង ទន្លេៈ**

ទន្លេជាមួយផ្នែកនៃទន្លេសេសាន្ត ដែលភាគច្រើនមានទឹករាក់នៅរដូវប្រាំង នៅរដូវវស្សាទឹកឡើងកំពស់ខ្លាំងដែលជាហេតុបណ្តាលអោយប៉ះពាល់ដល់ប្រជាជនស្ថិតនៅតាមដងទន្លេ និងប៉ះពាល់ដល់ផលដំណាំកសិករ។ ក្រៅពីទន្លេនៅមានស្ទឹងនិងអូរជាច្រើនទៀតដែលជាប្រភពទឹកសំរាប់ការប្រើប្រាស់ប្រចាំថ្ងៃនិងជាប្រភពសំរាប់ប្រើប្រាស់សំរាប់ដំណាំចំការ និងស្រែផងដែរ។

| លរ | ចំណាត់ថ្នាក់ប្រើប្រាស់ដីលំអិត | រូបភាពនៃការប្រើប្រាស់ដី |
|---|---|---|
| 1 | Code : 1200<br>ដីលំនៅដ្ឋានភូមិ |   |
| 2 | Code : 1210<br>កន្លែងកប់ខ្មោច |  |
| 3 | Code : 2110<br>ស្រូវវស្សា : ធ្វើស្រែវស្សា |   |
| 4 | Code : 2120<br>ដីកសិកម្មពនេចរ |   |

| | | |
|---|---|---|
| 5 | Code : 2200<br>ព្រៃស្រោងស្ងួត |  |
| 6 | ព្រៃល្បោះ |  |
| 7 | ព្រៃល្បោះស្ងួត |  |
| 8 | ព្រៃចំរុះ( ស្រោង និងរបោះ) |  |
| 9 | ព្រៃដុះឡើងវិញ |  |

| | | |
|---|---|---|
| 10 | វាលស្មៅ |  |
| 11 | ចំការបោះបង់ដុះស្មៅ |  |
| 12 | ព្រៃគម្ពោធ |  |
| 13 | ចំការបោះបង់ដុះព្រៃគម្ពោធ |  |

| | | |
|---|---|---|
| 14 | ព្រៃគម្ពោធលាយដើមឈើធំមួយៗ |  |
| 15 | បឹង |  |
| 16 | អូរ-ស្ទឹង-ទន្លេ |  |
| 17 | វាលភក់ |  |

# ឧបសម្ព័ន្ធ ២

## ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដីបច្ចុប្បន្ន (ផែនទីA-3)

| ល.រ | ចំណាត់ថ្នាក់នៃការគ្រប់គ្រង និងកាន់កាប់ដី | | ក្រឡាផ្ទៃ (ហិចតា) |
|---|---|---|---|
| | តាមច្បាប់អនុញ្ញាត្តិ និងតួនាទី | តាមចំណាត់ថ្នាក់ដីរដ្ឋ និងដីឯកជន | |
| ១ | សហគមន៍ព្រៃឈើប៉ុង | ដីសាធារណៈរបស់រដ្ឋ | ៣៨៦ |
| | ចំការបោះបង់ដុះព្រៃគម្ពោធ | ១កន្លែង | ១,២០ |
| | ព្រៃស្រោងសើម | ១កន្លែង | ៤,៨០ |
| | ព្រៃចំរុះ(ស្រោងនិងរបោះ) | ១កន្លែង | ២១២,00 |
| | ព្រៃដុះឡើងវិញ | ១កន្លែង | ៨៩,00 |
| | ព្រៃគម្ពោធលាយដើមឈើធំមួយៗ | ១កន្លែង | ៣៩,00 |
| ២ | តំបន់ការពារបឹងបានហ្វាំង | សាធារណៈរបស់រដ្ឋ | ផ្ទៃទឹក |
| ៣ | ផ្នែកនៃទន្លេសេសាន | សាធារណៈរបស់រដ្ឋ | ផ្ទៃទឹក |

ប្រភព: ទិន្នន័យGIS ប្រមូលពីមន្ទីរជនាញពាក់ព័ន្ធជុំវិញខេត្តរតនគីរី

## ឧបសម្ព័ន្ធ ៣

## បញ្ហាពាក់ព័ន្ធក្នុងការប្រើប្រាស់ដី (បញ្ហា/មូលហេតុ/ដំណោះស្រាយ)

| បញ្ហា | ទីតាំងនៃបញ្ហា | មូលហេតុ | ដំណោះស្រាយ |
|---|---|---|---|
| ១ | ២ | ៣ | ៤ |
| គ្មានត្រីហូប | បានហ្វាំង, ប៉ុង | ក-គ្មានស្រះចិញ្ចឹមត្រីតាមគ្រួសារ | ក-១ ជីកស្រះចិញ្ចឹមត្រីតាមគ្រួសារ |
| | | ខ-គ្មានវគ្គបណ្តុះបណ្តាលបច្ចេក ទេស ចិញ្ចឹមត្រីតាមគ្រួសារ | ខ-១ បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីតាមគ្រួសារ |
| | | គ-ត្រូវការផ្តល់ពូជត្រីចិញ្ចឹមតាម គ្រួសារ | គ-១ ផ្តល់ពូជត្រីចិញ្ចឹមតាមគ្រួសារ |
| | | ឃ-ត្រូវការអភិរក្សបឹង | ឃ-១ អភិរក្សបឹង |
| គ្មានប្រាក់ចំណូល | បានហ្វាំង, ប៉ុង | ក-គ្មានពូជមាន់ចិញ្ចឹមតាមគ្រួសារ | ក-១ ផ្តល់ពូជមាន់ចិញ្ចឹមតាមគ្រួសារ |
| | | ខ- គ្មានពូជទា ចិញ្ចឹមតាមគ្រួសារ | ខ-១ ផ្តល់ពូជទា ចិញ្ចឹមតាមគ្រួសារ |
| គ្មានពូជឈើហូបផ្លែដាំដុះ | បានហ្វាំង, ប៉ុង | ក-គ្មានពូជឈើហូបផ្លែគ្រប់មុខ | ក-១ ផ្តល់ពូជឈើហូបផ្លែគ្រប់មុខ |
| | | ខ-គ្មានសំភារៈកសិកម្មគ្រប់ព្រគាន់ | ខ-១ ផ្តល់សំភារៈកសិកម្មគ្រប់ព្រគាន់ |
| | | គ-គ្មានវគ្គបណ្តុះបណ្តាលបច្ចេក ទេសដាំដំណាំគ្រប់មុខនិងដំណាំ ឆ្លាស់ | គ-១ បណ្តុះបណ្តាលបច្ចេកទេសដាំដំណាំគ្រប់មុខ និង ដំណាំឆ្លាស់ |
| | | ឃ- គ្មានវគ្គបណ្តុះបណ្តាលបច្ចេក ទេសកសិកម្ម | ឃ-បណ្តុះបណ្តាលបច្ចេកទេសកសិកម្ម |

| | | | |
|---|---|---|---|
| ទិន្នផលស្រូវ ថយចុះ | បានហ្វាំង, ប៉ុង | ក-គ្មានពូជស្រូវដែលមានទិន្នផល ខ្ពស់ | ក-១ ផ្ដល់ពូជស្រូវដែលមានទិន្នផលខ្ពស់ |
| | | ខ- គ្មានប្រឡាយបង្ហូទឹក | ខ-១ ជីកប្រឡាយបង្ហូទឹក |
| | | គ-គ្មានវគ្គបណ្ដុះបណ្ដាលកសិករ ធ្វើជីកំប៉ុស្តិ៍ | គ-១ បណ្ដុះបណ្ដាលកសិករធ្វើជីកំប៉ុស្តិ៍ |
| | | ឃ- ដីគ្មានគុណភាព | ឃ-១ កែលំអរគុណភាពដីអោយមានជីជាតិ |
| | | ង- គ្មានម៉ាស៊ីនបូមទឹក | ង-១ ផ្ដល់ម៉ាស៊ីនបូមទឹក |
| សត្វមានជម្ងឺ | បានហ្វាំង, ប៉ុង | ក-គ្មានថ្នាំព្យាបាលសត្វ | ក-១ ផ្ដល់ថ្នាំព្យាបាលសត្វ |
| | | ខ-គ្មានការចាក់វ៉ាក់សាំងសត្វ | ខ-១ ចាក់វ៉ាក់សាំងសត្វ |
| | | គ-គ្មានវគ្គបណ្ដុះបណ្ដាលពេទ្យសត្វ ភូមិបន្ថែម | គ-១ បណ្ដុះបណ្ដាលពេទ្យសត្វភូមិបន្ថែម |
| | | ឃ-គ្មានការចុះតាមដានការពិនិត្យ ជំងឺសត្វជាប្រចាំ | ឃ-១ ចុះតាមដានការពិនិត្យជំងឺសត្វជាប្រចាំ |
| ពិបាកក្នុងការ ធ្វើដំណើរ | បានហ្វាំង, ប៉ុង | ក-គ្មានផ្លូវលំក្រាលគ្រួសក្រហម | ក-១ សាងសង់ផ្លូវលំក្រាលគ្រួសក្រហម |
| | | ខ-គ្មានស្ពានឈើឆ្លង់អូរ | ខ-១ សាងសង់ស្ពានឈើឆ្លង់អូរ |
| | | គ-គ្មានលូកាត់ផ្លូវ | គ-១ សាងសង់លូកាត់ផ្លូវ |
| សុខភាពសហគមន៍ថយចុះ | បានហ្វាំង, ប៉ុង | ក-គ្មានការចាក់វ៉ាក់សាំង៦មុខ ដល់ស្ត្រីនិងកុមារ | ក-១ ចាក់វ៉ាក់សាំង៦មុខដល់ស្ត្រីនិងកុមារ |
| | | ខ-បើកវគ្គបណ្ដុះបណ្ដាលអប់រំសុខ ភាពសហគមន៍ | ខ-១ បើកវគ្គបណ្ដុះបណ្ដាលអប់រំសុខភាពសហគមន៍ |
| | | គ- គ្មានការផ្សព្វផ្សាយការថែទាំ សុខភាពមាតា | គ-១ សាងសង់បង្គន់អានាម័យ |

| | | | |
|---|---|---|---|
| | | និងទារក | |
| សុខភាពសហគមន៍ថយចុះ | បានហ្វាំង, ប៉ុង | ក- គ្មានបង្គន់អានាម័យ | ក-១ សាងសង់បង្គន់អានាម័យ |
| | | ខ- គ្មានការផ្តល់ថ្នាំអាបែតដាក់ទឹក ប្រើប្រាស់ | ខ-១ ផ្តល់ថ្នាំអាបែតដាក់ទឹកប្រើប្រាស់ |
| | | គ- គ្មានការផ្តល់មុងជ្រលក់ថ្នាំ | គ-១ ផ្តល់មុងជ្រលក់ថ្នាំ |
| | | ឃ-គ្មានការថ្នាំការពន្យាកំណើត | ឃ-១ ផ្តល់ថ្នាំការពន្យាកំណើត |
| គ្មានទឹកស្អាតប្រើប្រាស់ | បានហ្វាំង, ប៉ុង | ក-គ្មានអណ្តូងទឹកស្អាត | ក-១ ជីកអណ្តូងទឹកស្អាត |
| | | ខ-គ្មានធុងចំរោះទឹកស្អាត | ខ-១ ផ្តល់ធុងចំរោះទឹកស្អាត |
| កុមារមិនចេះអក្សរ | បានហ្វាំង, ប៉ុង | ក-គ្មានការផ្សព្វផ្សាយអាណាព្យា បាលពីសារៈប្រយោជន៍តំលៃការ សិក្សា | ក-១ ផ្សព្វផ្សាយអាណាព្យាបាលពីសារៈប្រយោជន៍តំលៃការសិក្សា |
| | | ខ-គ្មានការជុំរុញឪពុកម្តាយឱ្យបញ្ជូនកូនចូលរៀន | ខ-១ ជុំរុញឪពុកម្តាយឱ្យបញ្ជូនកូនចូលរៀន |
| | | គ- គ្មានថ្នាក់អក្ខរៈកម្មតាមភូមិ | គ-១ បើកថ្នាក់អក្ខរៈកម្មតាមភូមិ |
| ព្រៃឈើថយចុះ | បានហ្វាំង, ប៉ុង | ក-គ្មានការពង្រឹងច្បាប់ការពារព្រៃឈើនិងសត្វព្រៃ | ក-១ ពង្រឹងច្បាប់ការពារព្រៃឈើនិងសត្វព្រៃ |
| | | ខ-គ្មានការផ្សព្វផ្សាយសារៈប្រយោជន៍ព្រៃឈើដល់សហគមន៍ | ខ-១ ផ្សព្វផ្សាយសារៈប្រយោជន៍ព្រៃឈើដល់សហគមន៍ |
| | | គ-គ្មានការទប់ស្កាត់ការជួញដូរសត្វ | គ-១ ទប់ស្កាត់ការជួញដូរសត្វព្រៃខុសច្បាប់ |

| | | | |
|---|---|---|---|
| | | ព្រៃខុសច្បាប់ | |
| | | ឃ- គ្មានគណៈកម្មការដកហូតការប្រើប្រាស់អាវុធខុសច្បាប់ | ឃ-១ បង្កើតគណៈកម្មការដកហូតការប្រើប្រាស់អាវុធខុសច្បាប់ |
| ចោរកម្ម | បានហ្វាំង, ប៉ុង | ក- គ្មានការពង្រឹងច្បាប់ប្រជាការពារដល់សហគមន៏ | ក-១ ពង្រឹងច្បាប់ប្រជាការពារដល់សហគមន៏ |
| | | ខ-គ្មានការទប់ស្កាត់ចោរកម្ម ផ្សេងៗ | ខ-១ ទប់ស្កាត់ចោរកម្មផ្សេងៗ |
| បាត់បង់ដីធ្លី | បានហ្វាំង, ប៉ុង | ក-គ្មានការបង្កើតគណៈកម្មការដោះស្រាយទំនាស់ដីធ្លី | ក-១ បង្កើតគណៈកម្មការដោះស្រាយទំនាស់ដីធ្លី |
| | | ខ- គ្មានវគ្គផ្សព្វផ្សាយសិទ្ធិមនុស្ស ដល់សគមន៏ | ខ-១ ផ្សព្វផ្សាយសិទ្ធិមនុស្សដល់សគមន៏ |
| | | គ- គ្មានប័ណកាន់កាប់ដីធ្លី | គ-១ ចេញប័ណ្ណកាន់កាប់ដីធ្លី |
| | | ឃ- គ្មានការផ្សព្វផ្សាយច្បាប់ភូមិបាលដល់សហគមន៏ | ឃ-១ ផ្សព្វផ្សាយច្បាប់ភូមិបាលដល់ សហគមន៏ |
| ស្រ្តីគ្មានជំនាញ | បានហ្វាំង, ប៉ុង | ក- គ្មានការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដល់ស្រ្តី | ក-១ បណ្ដុះបណ្ដាលវិជ្ជាជីវៈដល់ស្រ្តី |
| ស្រ្តីនិងកុមាររង់ គ្រោះអំពើហឹង្សា | បានហ្វាំង, ប៉ុង | ក-គ្មានការទប់ស្កាត់ការជួញដូរស្រ្តី និងកុមារ | ក-១ ទប់ស្កាត់ការជួញដូរស្រ្តី និងកុមារ |
| | | ខ-គ្មានការទប់ស្កាត់អំពើហឹង្សាក្នុង គ្រួសារ | ខ-១ ទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ |
| | | ក- គ្មានការវគ្គផ្សព្វផ្សាយបញ្ហាប | ក-១ វគ្គផ្សព្វផ្សាយបញ្ហាបយេនឌ័រដល់សហគមន៏ |

| | | | |
|---|---|---|---|
| ស្ត្រីនិងបុរសពុំទាន់មានតម្លាភាព | បានហ្វាំង, ប៉ុង | យេនឌ័រដល់សហគមន៍ | |
| | | ខ-គ្មានវគ្គវគ្គបណ្តុះបណ្តាល យេនឌ័រ | ខ-១ បើកវគ្គបណ្តុះបណ្តាលយេនឌ័រ |
| | | គ-គ្មានការអប់រំតួនាទីបុរសនិង ស្ត្រីក្នុសង្គម | គ-១ អប់រំតួនាទីបុរសនិងស្ត្រីក្នុសង្គម |
| ស្ត្រីក្រុមប្រឹក្សាឃុំមានកំរិត | | ក-គ្មានការពង្រឹងសមត្ថភាពជនបង្គោលទទួលបន្ទុកស្ត្រីនិងកុមារ | ក-១ ពង្រឹងសមត្ថភាពជនបង្គោលទទួលបន្ទុកស្ត្រី និងកុមារ |

## ឧបសម្ព័ន្ធ ៤

## គ្រូបខំណត់នៃការអភិវឌ្ឍន៍ និងចំរើសនៃការប្រើប្រាស់ដីធ្លីអនាគត

## កំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និងយុទ្ធសាស្ត្រ (តារាង)

| តម្រូវការនៃ ការអភិវឌ្ឍន៍ | ប្រភពឯកសារ | គោលដៅនៃ ការអភិវឌ្ឍន៍ | យុទ្ធសាស្ត្រនៃ ការអភិវឌ្ឍន៍ | សកម្មភាពជា អាទិភាព | លេខរៀងនៅ លើផែនទី |
|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| មានបច្ចេកទេសចិញ្ចឹមត្រី | ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ ប៉ុង ស្រុកវឺនសៃ ខេត្តរតនគិរី | - ប្រជាពលរដ្ឋ-ប្រុស-ស្រី-ក្មេង-ចាស់-ឆ្នាំ<br>- ២០០៨-២០១២-<br>- ទទួលបានទិន្នផលស្រូវខ្ពស់ មានផ្លែឈើ និងត្រីហូប លក់បានជាប្រចាំ<br>- មានប្រព័ន្ធស្រោចស្រព ដំណាំស្រូវ និងដំណាំ | លើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ | - ជីកស្រះចិញ្ចឹមត្រីតាមគ្រួសារ<br>- បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីតាមគ្រួសារ<br>- ផ្តល់ពូជត្រីចិញ្ចឹមតាមគ្រួសារ អភិរក្សបឹង | |
| មានបច្ចេកទេសចិញ្ចឹមសត្វ មាន់-ទា | ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ ប៉ុង ស្រុកវឺនសៃ ខេត្តរតនគិរី | - កសិកម្មគ្រប់មុខបានគ្រប់គ្រាន់<br>- មានជីវភាពធូធារបានល្អ | បង្កើនប្រាក់ចំណូល | - ផ្តល់ពូជមាន់ ចិញ្ចឹមតាមគ្រួសារ<br>- ផ្តល់ពូជទា ចិញ្ចឹមតាមគ្រួសារ | |

| | | | | | |
|---|---|---|---|---|---|
| មានបច្ចេកទេសដាំដំណាំ | ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ ប៉ុង ស្រុកវឺនសៃ ខេត្តរតនគិរី | ប្រសើរ<br>-ទិន្នផលដំណាំឈើហូបផ្លែ ខ្ពស់ | លើកកំពស់ទិន្នផលដំណាំឈើហូបផ្លែ | ផ្តល់ស្បៀងដល់ប្រជាពលរដ្ឋក្រីក្រ<br>ផ្តល់ពូជឈើហូបផ្លែគ្រប់មុខ<br>ផ្តល់សំភារៈកសិកម្មគ្រប់គ្រាន់<br>បណ្តុះបណ្តាលបច្ចេកទេសដាំដំណាំគ្រប់មុខ | |
| ចេះបច្ចេកទេសក្នុងការធ្វើផលិតកម្មដំណាំស្រូវ | ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ ប៉ុង ស្រុកវឺនសៃ ខេត្តរតនគិរី | -ទិន្នផលស្រូវខ្ពស់ | -លើកកំពស់ទិន្នផលដំណាំស្រូវ | -<br>បណ្តុះបណ្តាលបច្ចេកទេសកសិកម្ម<br>-<br>ផ្តល់ពូជស្រូវដែលមានទិន្នផលខ្ពស់<br>- ជីកប្រឡាយបង្ហូរទឹក<br>- បណ្តុះបណ្តាលកសិករធ្វើជីកំប៉ុស្តិ៍<br>-កែលំអរគុណភាពដីអោយមានជីជាតិ<br>- ផ្តល់ម៉ាស៊ីនបូមទឹក | |

| | | | | | |
|---|---|---|---|---|---|
| ពេទ្យសត្វមានសមត្ថភាព និងលទ្ធភាព | ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំប៉ុង ស្រុកវឺនសៃ ខេត្តរតនគិរី | -ប្រជាជនមានកំលាំងអូសទាញគ្រប់គ្រាន់<br>- សុខភាពសត្វមានសុខភាពល្អ<br>-ការបង្ករបង្កើនផលមានភាពងាយស្រួល ចំណេញពេលវេលា ។ | - បង្កើនសមត្ថភាព និង លទ្ធភាពដល់ពេទ្រសត្វ | - ផ្តល់ថ្នាំព្យាបាលសត្វ<br>- ចាក់វ៉ាក់សាំងសត្វ<br>- បណ្តុះបណ្តាលពេទ្យសត្វភូមិបន្ថែម<br>- ចុះតាមដានការពិនិត្យជំងឺសត្វជាប្រចាំ | |
| មានផ្លូវងាយស្រួលក្នុងការធ្វើដំណើរ | ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំប៉ុង ស្រុកវឺនសៃ ខេត្តរតនគិរី | -ប្រជាពលរដ្ឋមានផ្លូវ ធ្វើដំណើរងាយស្រួល<br>-ការទំនាក់ទំនង និង ប្រកបមុខរបរប្រចាំថ្ងៃបានល្អប្រ សើរ | -កែលំអរហេដ្ឋារចនាសម្ព័ន្ធផ្លូវលំ | - សាងសង់ផ្លូវលំក្រាលគ្រួសក្រហម<br>- សាងសង់ស្ពានឈើឆ្លងអូរ<br>- សាងសង់លូកាត់ផ្លូ | |
| សហគមន៍មានសុខភាពល្អ និងផ្តល់សេវាបានល្អ | ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំប៉ុង ស្រុកវឺនសៃ ខេត្តរតនគិរី | - ប្រជាពលរដ្ឋ ឆ្នាំ ២០០៨ -២០១២ ទទួលបានសេវាសុខភាព<br>- ប្រជាពលរដ្ឋមានសុខភាព ល្អ | - កាត់បន្ថយអត្រាគ្រោះថ្នាក់ប្រជាពលរដ្ឋក្នុងសហគមន៍<br>- បង្កើនចំណេះដឹងបន្ថែមដល់ប្រជាពលរដ្ឋពីការអនាម័យ និង | - ចាក់វ៉ាក់សាំង ៦មុខដល់ស្ត្រី និងកុមា<br>- បើកវគ្គបណ្តុះបណ្តាលអប់រំសុខភាពដល់សហគមន៍<br>- ផ្សព្វផ្សាយការថែទាំសុខភាពមាតា | |

| | | | | | |
|---|---|---|---|---|---|
| | | | សុខភាព | និងទារក<br>- សាងសង់បង្គន់អនាម័យ<br>-ផ្តល់ថ្នាំអាបែតដាក់ទឹកប្រើប្រាស់<br>- ផ្តល់មុងជ្រកលថ្នាំ<br>- ផ្តល់ថ្នាំបន្សាកំណើត<br>- ជីកអណ្តូងទឹកស្អាត<br>- ផ្តល់ធុងចំរោះទឹកស្អាត | |
| កុមារគ្រប់អាយុបានចូលរៀន | ផែនការអភិវឌ្ឍន៏ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ ប៉ុង ស្រុកវ៉ឺនសៃ ខេត្តរតនគីរី | - កុមារា កុមារី មានចំណេះ ដឹង និងមានធនធានមនុស្ស | - លើកកំពស់វិស័យអប់រំ | -<br>ផ្សព្វផ្សាយអាណាព្យាបាលពីតំលៃនៃការសិក្សា<br>- ជំរុញឳពុកម្តាយអោយបញ្ជូនកូនមកសាលា<br>- បើកថ្នាក់អក្ខរៈកម្មតាមភូមិ | |
| ពង្រឹងច្បាប់ការពារព្រៃឈើ និងសត្វព្រៃ | ផែនការអភិវឌ្ឍន៏ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ ប៉ុង ស្រុកវ៉ឺនសៃ ខេត្តរតនគីរី | ព្រៃឈើ និងសត្វព្រៃគង់វង្ស | -ពង្រឹងវិស័យព្រៃឈើ និងសត្វព្រៃ | - ពង្រឹងវិស័យព្រៃឈើ និងសត្វព្រៃ | |
| ព្រៃឈើ និងសត្វព្រៃត្រូវបាន អភិរក្សបានល្អ | ផែនការអភិវឌ្ឍន៏ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ | -អនុផលព្រៃឈើ និង បាន ប្រើប្រាស់ប្រកបដោយនិរន្តរភា | -ពង្រឹងវិស័យព្រៃឈើ និងសត្វព្រៃ | - ពង្រឹងច្បាប់ការពារព្រៃឈើ និងសត្វព្រៃ | |

| | | | | | |
|---|---|---|---|---|---|
| | ប៉ុង ស្រុកវីនសៃ ខេត្តរតនគីរី | ៣ ប្រជាពលរដ្ឋទទួលបានកំរៃជាប្រចាំ<br>- សត្វព្រៃសំបូរឡើងវិញ | | - ផ្សព្វផ្សាយសារៈប្រយោជន៍ព្រៃឈើដល់សហគមន៍<br>- ទប់ស្កាត់ការជួញដូរសត្វព្រៃខុសច្បាប់ ។ | |
| ធនធានមច្ឆាជាតិត្រូវបានអភិរក្ស | ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ ប៉ុង ស្រុកវីនសៃ ខេត្តរតនគីរី | - មានត្រីបរិភោគគ្រប់គ្រាន់ | - ពង្រឹងវិស័យជលផល | - បង្កើតគណៈកម្មការដកហូតការប្រើប្រាស់អាវុធខុសច្បាប់<br>- ទប់ស្កាត់ការនេសាទត្រីនៅរដូវត្រីពង<br>- ទប់ស្កាត់ការនេសាទត្រីប្រើឧបករណ៍ខុសច្បាប់<br>- ផ្សព្វផ្សាយច្បាប់ជលផល<br>- បង្កើតសហគមន៍ជលផល | |
| សុវត្ថិភាព និងសណ្តាប់ធ្នាប់ សង្គម | ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ ប៉ុង ស្រុកវីនសៃ ខេត្តរតនគីរី | - ប្រជាពលរដ្ឋមាន សុវត្ថិភាព សណ្តាប់ធ្នាប់ សង្គមបានល្អប្រសើរ | - ពង្រឹងច្បាប់ប្រជាការពារ | - ពង្រឹងច្បាប់ប្រជាការពារដល់សហគមន៍<br>- ទប់ស្កាត់ចោរកម្មផ្សេងៗ<br>- ផ្សព្វផ្សាយសិទ្ធិមនុស្សដល់ | |

| | | | | | |
|---|---|---|---|---|---|
| | | | | សហគមន៍ | |
| ប័ណ្ណកម្មសិទ្ធដីធ្លីស្របច្បាប់ | ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ ប៉ុង ស្រុកវឹនសៃ ខេត្តរតនគិរី | - ប្រជាពលរដ្ឋមានប័ណ្ណកម្មសិទ្ធដី និងកាត់បន្ថយទំនាស់ដីធ្លី | - បង្រឹងច្បាប់ភូមិបាល | - បង្កើតគណៈកម្មការដោះស្រាយទំនាស់ដីធ្លី<br>- ចេញប័ណ្ណកាន់កាប់ដីធ្លី<br>- ផ្សព្វផ្សាយច្បាប់ភូមិបាលដល់សហគមន៍ | |
| ស្ត្រីត្រូវបានគេគោរព និងមានតួនាទីច្រើនក្នុងសង្គម ។ | ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ ប៉ុង ស្រុកវឹនសៃ ខេត្តរតនគិរី | - ស្ត្រី និងកុមារជៀសផុតការគ្រោះថ្នាក់ពីបុរស<br>- បុរស និងស្ត្រីមានភាព ស្មើគ្នា និងទទួលបានការបព្រាបយេនឌ័រដោយ តម្លាភាព | - ពង្រឹងច្បាប់អំពើហឹង្សាក្នុងគ្រួសារ<br>- ពង្រឹងច្បាប់ការជួញដូរស្ត្រីភេទ<br>- បង្កើនចំណេះដឹងដល់ស្ត្រី<br>- ពង្រឹងតួនាទីយេនឌ័រក្នុងសង្គម | - ទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ<br>- ទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ<br>- វគ្គផ្សាព្វផ្សាយបព្រាបយេនឌ័រដល់សហគមន៍<br>- បណ្តុះបណ្តាលវិជ្ជាជីវៈដល់ស្ត្រី<br>- អប់រំតួនាទីបុរស និងស្ត្រីក្នុងសង្គម<br>- ពង្រឹងសមត្ថភាពជនបង្គោលទទួលបន្ទុកស្រី និងកុមារ | |

## ឧបសម្ព័ន្ធ ៥

## បញ្ជីគំរោង ឬសកម្មភាពសំខាន់របស់ឃុំ ក្នុងរយៈពេល ១៥ឆ្នាំ

| ល.រ | គំរោង ឬសកម្មភាព | លទ្ធផលគ្រោង | | ផែនការប្រើប្រាស់ដីធ្លី ១៥ ឆ្នាំ | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ចំនួន | ឯកត្តា | ៥ឆ្នាំទី១[១] | ៥ឆ្នាំទី២[២] | ៥ឆ្នាំទី៣[៣] | |
| ២.៦.១. | គំរោងផ្នែកហេដ្ឋរចនាសម្ព័ន្ធ | | | | | | |
| | **២.៦.១.១. គំរោងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត** | | | | | | |
| | **១.១. ផ្លូវថ្នល់** | | | | | | |
| | ១.១.១. ផ្លូវក្រាលកៅស៊ូ ( ២ ខ្សែ ) | ២៨.៥០ | គ.ម | ៨.៥០ | ១០ | ១០ | |
| | ១.១.២. ផ្លូវក្រាលគ្រួសក្រហមនិងជួសជុល ( ០៥ ខ្សែ ) | ១៦.00 | គ.ម | ៦.00 | ៥ | ៥ | |
| | ១.១.៣. ប្រវែងផ្លូវក្រាលដីស | 0 | គ.ម | 0 | 0 | 0 | |
| | ១.១.៤. ផ្លូវរទេះ/ថ្មើជើង | 0 | 0 | 0 | 0 | 0 | |
| | **១.២. ប្រព័ន្ធស្រោចស្រព** | | | | | | |
| | ១.២.១. ប្រឡាយមេ | ២.៥0 | គ.ម | ២.៥0 | 0 | 0 | |
| | ១.២.២. ប្រឡាយរង | ៣ | គ.ម | ៣ | 0 | 0 | |

(១) - ៥ឆ្នាំទី១ (២00៨-២០១២): បញ្ចូលគំរោងទាំងអស់របស់ **CDP** ឆ្នាំ ២00៨-២០១២ រួមទាំងគំរោងផ្នែកប្រើប្រាស់ដីដែលបានបង្កើតក្នុង **CLUP** ផងដែរ (៥ ឆ្នាំទី១)

(២) - ៥ឆ្នាំទី២ (២០១៣-២០១៧): គំរោងទាំងឡាយនៃផែនការប្រើប្រាស់ដីធ្លីឃុំ **CLUP** សំរាប់អោយឃុំប្រើជាមូលដ្ឋានក្នុងការកសាង **CDP** ៥ឆ្នាំបន្ទ (៥ ឆ្នាំទី២)

(៣) - ៥ឆ្នាំទី៣ (២០១៨-២0២២): គំរោងទាំងឡាយនៃផែនការប្រើប្រាស់ដីធ្លីឃុំ **CLUP** សំរាប់អោយឃុំប្រើជាមូលដ្ឋានក្នុងការកសាង **CDP** ៥ឆ្នាំបន្តទៀត (៥ ឆ្នាំទី៣)

| | | | | | | | |
|---|---|---|---|---|---|---|---|
| | **១.៣. ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត** | | | | | | |
| | ១.៣.១. ចំនួន ស្ពានថ្ម | 0 | កន្លែង | 0 | 0 | 0 | |
| | ១.៣.២. ចំនួនស្ពានឈើ | ៣ | កន្លែង | ១ | ២ | 0 | |
| | ១.៣.៣. ចំនួន ទ្វារទឹក | ១0 | កន្លែង | ៥ | ៥ | ២ | |
| | ១.៣.៤. ចំនួនលូឆ្លងផ្លូវ | ១១ | កន្លែង | ៤ | ៤ | ៣ | |
| | ១.៣.៥. ផ្សេងៗ | | | | | | |
| | **២.៦.១.២. ហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេវាកម្មផ្សេងៗ** | | | | | | |
| | ២.៦.១.២.១. ការសិក្សា និងអប់រំ | | | | | | |
| | ២.៦.១.២.២. សាលាមត្តេយ្យ | ២ | អាគារ | ១ | ១ | 0 | |
| | ២.៦.១.២.៣. សាលាបឋមសិក្សា | ២ | អាគារ | 0 | ១ | ១ | |
| | ២.៦.១.២.៤. សាលាមធ្យមសិក្សា | ២ | អាគារ | ១ | ១ | 0 | |
| | ២.៦.១.២.៥. សាល ស្នាក់ការសហគមន៍នេសាទ វិទ្យាល័យ | ១ | កន្លែង | ១ | 0 | 0 | |
| | ២.៦.១.២.៦. ស្នាក់ការសហគមន៍នេសាទ | ២ | កន្លែង | ១ | ១ | 0 | |
| | **២.៦.១.៣. សុខភាព និងអនាម័យ** | | | | | | |
| | ២.៦.១.៤. មណ្ឌលសុខភាព | 0 | កន្លែង | 0 | 0 | 0 | |
| | ២.៦.១.៥. ប៉ុស្តិសុខភាព | ១ | កន្លែង | ១ | 0 | 0 | |
| | ២.៦.១.៦. ស្រះទឹកស្អាត | ២0 | ស្រះ | ៥ | ៥ | ១0 | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ២.៦.១.៧. អណ្តូងទឹកស្អាត | ៤៧ | អណ្តូង | ២០ | ១៥ | ១២ | |
| | ២.៦.១.៨. សាងសង់បង្គន់អនាម័យ | ៥០ | កន្លែង | ២០ | ១៥ | ១៥ | |
| | ២.៦.១.៩. កន្លែងចាក់សំរាម | ២ | កន្លែង | ១ | ១ | ០ | |
| | **២.៦.១.៤. សន្តិសុខ និងសណ្តាប់ធ្នាប់** | | | | | | |
| | ២.៦.១.៤.១. ប៉ុស្តិ៍នគរបាល | ១ | ០ | ១ | ០ | ០ | |
| | ២.៦.១.៤.២. ទីតាំងផ្សារ | ០ | កន្លែង | ០ | ០ | ០ | |
| | **២.៦.១.៥. កន្លែងគោរពបូជា** | | | | | | |
| | ២.៦.១.៥.១. ទីកន្លែងសាការៈបូជា | ០ | កន្លែង | ០ | ០ | ០ | |
| | ២.៦.១.៥.២. វត្តព្រះអារាម | ០ | កន្លែង | ០ | ០ | ០ | |
| | ២.៦.១.៥.៣. សាលាឆទាន | ២ | កន្លែង | ១ | ១ | ០ | |
| ២.៦.២. | គំរោងផ្នែកប្រើប្រាស់ដីធ្លី | | | | | | |
| | **២.៦.២.១. គំរោងប្រើប្រាស់ដីតាមវិស័យធំៗ** | | | | | | |
| | ២.៦.២.១.១. តំបន់អភិរក្សសត្វព្រៃ | ៦០១ | ហិកតា | ៦០១ | ០ | ០ | |
| | ២.៦.២.១.២. ដីសម្បទានសង្គមកិច្ច | ២៣៧ | ០ | ៣៧ | ១០០ | ១០០ | |
| | **២.៦.២.២. គំរោងប្រើប្រាស់ដីលក្ខណៈសហគមន៍ភូមិ-ឃុំ** | | | | | | |
| | ២.៦.២.២.១. ដីភូមិ | ២៤៩.៦០ | ហិកតា | ៤៩.៦០ | ១០០ | ១០០ | |
| | ២.៦.២.២.២. ដីអាស្រមសំរាប់តំកល់សព | ០.៥០ | ០ | ០.៥០ | ០ | ០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ២.៦.២.២.៣. ដីកសិកម្ម | ៦៤២ | ហិកតា | ២០០ | ២០០ | ២៤២ | |
| | ២.៦.២.២.៤. ផ្សេងៗ | | | | | | |